**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ផែនការអភិវឌ្ឍន៍ស្ថាប័ន
# របស់និយ័តករធានារ៉ាប់រងកម្ពុជា
## ២០២១-២០២៥

**បានទទួលការអនុម័តក្នុងកិច្ចប្រជុំក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**
**នាសម័យប្រជុំលើកទី៩ អាណត្តិទី១**

ថ្ងៃអង្គារ ៣កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ត្រូវនឹងថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២

រៀបចំដោយ

**និយ័តករធានារ៉ាប់រងកម្ពុជា**

**នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

# អារម្ភកថា

ក្នុងដំណាក់កាលដែលកម្ពុជាកំពុងតែធ្វើដំណើរចាកចេញពីឋានៈប្រទេសមានចំណូលទាបទៅកាន់ប្រទេសមានចំណូលមធ្យមកម្រិតទាប រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ ក្នុងន័យបង្កើតបានជាចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំក្នុងរយៈពេលមធ្យមនិងរយៈពេលវែង។ តាមរយៈឯកសារគោលនយោបាយ "**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤**" រាជរដ្ឋាភិបាលបានសង្កត់ធ្ងន់លើកិច្ចការធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយបានកំណត់នូវអាទិភាពចំនួន ០៤ សំខាន់ៗ គឺ÷ **១).** ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល **២).** ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ **៣).** ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងការឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្ម៤.១ និង **៤).** ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ។

ដើម្បីចូលរួមអនុវត្តកម្មវិធីគោលនយោបាយខាងលើរបស់រាជរដ្ឋាភិបាល និយ័តករធានារ៉ាប់រងកម្ពុជា បានរៀបចំ "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០**" ដែលបានទទួលការអនុម័តដាក់ឱ្យប្រើប្រាស់ ដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ និងបានបន្តរៀបចំនូវ "**ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥**" សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋ ក្នុងការរួមចំណែកកសាងមូលដ្ឋានគ្រឹះចាំបាច់នៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីរុញច្រាននាវាកម្ពុជាឆ្ពោះទៅរកគោលដៅនៃ "**ចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និង ឆ្នាំ២០៥០**"។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥ នឹងបំពេញតួនាទីជាឯកសារក្របខណ្ឌគោល-នយោបាយគ្រប់ជ្រុងជ្រោយ មានភាពប្រទាក់ក្រឡាគ្នាយ៉ាងជិតស្និទ្ធ និងបំពេញឱ្យគ្នាទៅវិញទៅមកតាមរយៈការកំណត់សកម្មភាពការងារអាទិភាព ជាមួយនឹងពេលវេលាដែលបានកំណត់ច្បាស់លាស់សម្រាប់

ការអនុវត្តដោយមានសង្គតិភាពជាមួយនឹងទិសដៅនៃឯកសារគោលនយោបាយដទៃទៀតរបស់រាជរដ្ឋាភិបាល ផងដែរ។

វិស័យធានារ៉ាប់រងដែលជាផ្នែកមួយនៃវិស័យសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានសក្តានុពលជាច្រើនសម្រាប់យកមកធ្វើជាមូលដ្ឋានក្នុងការអភិវឌ្ឍ ដោយឆ្លុះបញ្ចាំងតាមរយៈកត្តាផលលាភប្រជាសាស្ត្រ គួបផ្សំជាមួយនឹងការបន្តកើនឡើងនៃចំនួនប្រជាជនដែលមានចំណូលមធ្យមនៅកម្ពុជាផងដែរ។ ជាមួយនឹងអត្រាអ្នកប្រើប្រាស់អ៊ីនធឺណិតខ្ពស់នៅកម្ពុជា ការទាញយកផលប្រយោជន៍ពីភាពរីកចម្រើននៃបច្ចេកវិទ្យា និងការធ្វើនវានុវត្តន៍លើវិស័យធានារ៉ាប់រង គឺជាកូនសោរសម្រាប់ធ្វើទំនើបកម្មស្ថាប័នលើគ្រប់ទិដ្ឋភាព រួមបញ្ចូលទាំងពេលវេលានៃការផ្តល់សេវាសាធារណៈ ភាពងាយស្រួលនៃការស្នើសុំនិងការទទួលបានសេវា គុណភាពនៃសេវា និងភាពគ្រប់ដណ្តប់នៃសេវា។ ទាំងនេះបានពង្រឹងបន្ថែមនូវកាលានុវត្តភាពថ្មីៗ សម្រាប់ការអភិវឌ្ឍទាំងវិស័យនិងស្ថាប័នធានារ៉ាប់រងនៅកម្ពុជា ក្នុងការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅរបស់ខ្លួន។

ក្នុងន័យនេះ ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥ នឹងក្លាយជាមគ្គុទេសក៏ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពការងាររបស់និយ័តករធានារ៉ាប់រងកម្ពុជា ក្នុងគោលដៅបន្តដំណើរឆ្ពោះទៅមុខសម្រាប់រយៈពេលមធ្យម ដោយឈរលើ**សសរស្តម្ភទាំងបី** (ឬហៅថា 3Cs)÷ **សមត្ថភាពស្ថាប័ន (Capacity) ការតភ្ជាប់ (Connectivity) និងកិច្ចសហប្រតិបត្តិការ (Cooperation)**។ គោលដៅចម្បងនៃការអភិវឌ្ឍស្ថាប័ននេះ ត្រូវធានាបាននូវភាពរឹងមាំនៃសមត្ថភាពស្ថាប័ន និងប្រសិទ្ធភាពនៃការបំពេញមុខងារ ការសម្របសម្រួលអន្តរស្ថាប័ន ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ស្ថាប័ន ។

នៅចុងបញ្ចប់ ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់និយ័តករធានារ៉ាប់រងកម្ពុជាដែលបានរៀបចំនូវ "**ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥**" ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងការបំពេញមុខងារឯករាជ្យរបស់ស្ថាប័នប្រកបដោយគុណភាព សមត្ថភាព និងផលិតភាព ក្នុងន័យរួមចំណែកក្នុងការធានាបាននូវភាពប្រកួតប្រជែងខ្ពស់នៃវិស័យធានារ៉ាប់រងទាំងមូល។ ឆ្លៀតឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណជូន ឯកឧត្តម **ម៉ៅ ច័ន្ទតារី** អគ្គនាយកនៃនិយ័តករ

ធានារ៉ាប់រងកម្ពុជា និងក្រុមការងារបច្ចេកទេសទាំងអស់ដែលបានដឹកនាំនិងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ឱ្យសម្រេចបានជោគជ័យ។

ថ្ងៃ សុក្រ ១២ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

ផ្នែកទី ១ ÷ សេចក្តីផ្តើម ........ 1

១.១. ទិដ្ឋភាពទូទៅ ........ 1

១.២. សារៈតានៃការវិវត្តស្ថាប័ននិយ័តករធានារ៉ាប់រង ........ 2

១.៣. រចនាសម្ព័ន្ធបច្ចុប្បន្ននៃនិយ័តករធានារ៉ាប់រងកម្ពុជា ........ 4

១.៤. សមិទ្ធផលសម្រេចបាន ........ 5

ផ្នែកទី ២÷ ទស្សនវិស័យសម្រាប់អភិវឌ្ឍស្ថាប័ន ........ 7

២.១. ការវាយតម្លៃស្ថានភាពបច្ចុប្បន្ន (SWOT Analysis) ........ 7

២.២. កត្តាកំណត់ទិសដៅអភិវឌ្ឍស្ថាប័ន ........ 8

ផ្នែកទី ៣ ÷ ចក្ខុវិស័យ គោលបំណង និងគោលដៅ ........ 9

៣.១. ចក្ខុវិស័យ ........ 9

៣.២. គោលបំណង និងគោលដៅ ........ 10

ផ្នែកទី ៤ ÷ ផែនការសកម្មភាព ........ 10

៤.១. ក្របខណ្ឌយុទ្ធសាស្ត្រ ........ 11

៤.២. គោលការណ៍នៃការរៀបចំសកម្មភាពការងារ ........ 12

៤.៣. សកម្មភាពការងារ ........ 13

ផ្នែកទី ៥ ÷ យន្តការអនុវត្តន៍ ការត្រួតពិនិត្យ និងការវាយតម្លៃ ........ 20

៥.១. យន្តការអនុវត្តន៍ ........ 20

៥.២. ការត្រួតពិនិត្យ និងការវាយតម្លៃ ........ 20

ផ្នែកទី ៦ ÷ សន្និដ្ឋាន ........ 21

ផ្នែកទី ៧÷ តារាងសកម្មភាពការងារនៃផែនការអភិវឌ្ឍន៍ស្ថាប័ន ........ 23

# ផ្នែកទី ១ ÷ សេចក្តីផ្តើម

## ១.១. ទិដ្ឋភាពទូទៅ

កន្លងមក រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ជាច្រើន ដែលក្នុងនោះមានការធានាបាននូវស្ថិរភាពនយោបាយពេញលេញ កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាមធ្យមជាង ៧% ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រ ការកែទម្រង់អភិបាលកិច្ចនិងកំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលដៅសូចនាករផ្នែកសង្គមសំខាន់ៗស្របតាមកម្មវិធីនៃគោលនយោបាយនិងចក្ខុវិស័យវែងឆ្ងាយនិងប្រាកដនិយម ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

វិស័យហិរញ្ញវត្ថុ ដែលជាវិស័យមួយមានសន្ទុះរីកចម្រើនឆាប់រហ័ស បានរួមចំណែកក្នុងសមិទ្ធផលសំខាន់ៗខាងលើផងដែរ ដោយសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុចាប់តាំងពីឆ្នាំ២០០១។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ និងចុងក្រោយបានប្រែក្លាយជា **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ (២០១៦-២០២៥)"** ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងនៃវឌ្ឍនភាពទីផ្សារ ដោះស្រាយវិបត្តិទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព និងរក្សាបាននូវស្ថិរភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុក្នុងប្រទេសល្អប្រសើរ។

ជាមួយគ្នានេះ វិស័យធានារ៉ាប់រងដែលជាផ្នែកមួយនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ក៏បានដើរតួនាទីយ៉ាងសកម្មក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងរួមចំណែកទ្រទ្រង់វិស័យសន្តិសុខសង្គម ដោយបង្កើតឱកាសការងារជូនប្រជាជន ជាប្រភពហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ជាឧបករណ៍សម្រាប់ការការពារហានិភ័យលើបន្ទុកហិរញ្ញវត្ថុ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន។

វិស័យធានារ៉ាប់រងនៅកម្ពុជា បានផ្តើមចេញពីទីផ្សារមួយតូចចង្អៀតដែលមាន ក្រុមហ៊ុនរដ្ឋតែ ១ ប៉ុណ្ណោះ ជាមួយនឹងក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន ៣ នៅក្នុងដើមទស្សវត្សរ៍ទី៩០ និងបានប្រែក្លាយមុខមាត់ទៅជាវិស័យមួយដែលប្រកបដោយសក្តានុពល ដោយបច្ចុប្បន្នមានគ្រឹះស្ថានធានារ៉ាប់រងចំនួន ៨០ មានបុគ្គលជាភ្នាក់ងារធានារ៉ាប់រងចំនួនជាង ៥០០០នាក់ មានទ្រព្យសកម្មសរុបចំនួនប្រមាណ ៨៤៥ លានដុល្លារអាមេរិក និងមានមូលនិធិភាគទុនិកចំនួនប្រមាណ ៣៧៨ លានដុល្លារអាមេរិក ជាមួយនឹងបុព្វលាភធានារ៉ាប់រងដុលប្រមាណ ២៩៨ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២១។ ជាមួយនឹងការកើនឡើងនៃទំហំទីផ្សារធានារ៉ាប់រងកម្ពុជាក្នុងឆ្នាំ២០២១ វិស័យធានារ៉ាប់រងបានរួមភាគទានក្នុងសេដ្ឋកិច្ច (Insurance Penetration Rate) ជាអត្រាប្រមាណ ១.១០% ជាមួយដង់ស៊ីតេធានារ៉ាប់រង

(Insurance Density) ប្រមាណ ១៨.៦១ ដុល្លារអាមេរិកក្នុងមនុស្សម្នាក់ៗ។ ការរីកចម្រើននៃវិស័យធានារ៉ាប់រងនៅកម្ពុជា បន្តមានសញ្ញាណវិជ្ជមានគួរឱ្យកត់សម្គាល់ បើទោះបីជាស្ថិតក្នុងដំណាក់កាលនៃការឆ្លងរាលដាលដោយជំងឺកូវីដ-១៩ ដែលនេះបង្ហាញឱ្យឃើញពីសារៈសំខាន់នៃសេវាធានារ៉ាប់រងដែលគាំទ្រដល់វិស័យសន្តិសុខសង្គម និងឆ្លុះបញ្ចាំងពីភាពរឹងមាំនៃការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

ជាការឆ្លើយតបទៅនឹងការអភិវឌ្ឍវិស័យធានារ៉ាប់រងយ៉ាងឆាប់រហ័ស ក៏ដូចជាការរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ និងការបន្តកើនឡើងនៃតម្រូវការសេវាធានារ៉ាប់រងនៅកម្ពុជា និយ័តករធានារ៉ាប់រងកម្ពុជាបានសម្លឹងឃើញពីសារៈសំខាន់នៃការរៀបចំឱ្យមាននូវ **“ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥”** ក្នុងគោលបំណងប្រែក្លាយ និយ័តករធានារ៉ាប់រងកម្ពុជា ទៅជាស្ថាប័ននិយ័តកម្មឯករាជ្យមួយដែលមានសមត្ថភាពប្រកបដោយវិជ្ជាជីវៈនិងទទួលបានជំនឿទុកចិត្តខ្ពស់ពីសំណាក់មហាជន។ ផែនការនេះ កំណត់គោលដៅយុទ្ធសាស្ត្របីសំខាន់ៗ (ហៅថា 3Cs) រួមមាន៖ **សមត្ថភាពស្ថាប័ន (Capacity), ការតភ្ជាប់ (Connectivity) និងកិច្ចសហប្រតិបត្តិការ (Cooperation)** និងផ្អែកលើគោលការណ៍ SMART (Specific, Measurable, Achievable, Relevant, Time-bound) ក្នុងការរៀបចំសកម្មភាពការងារសម្រាប់អនុវត្ត ដើម្បីឈានទៅសម្រេចបាននូវគោលដៅសូចនាកររួមពីរ សម្រាប់វាស់ការរីកចម្រើននៃវិស័យធានារ៉ាប់រងកម្ពុជានៅឆ្នាំ២០២៥ គឺអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច (Insurance Penetration Rate) **២%** និងដង់ស៊ីតេធានារ៉ាប់រង (Insurance Density) **៤០ដុល្លារក្នុងមនុស្សម្នាក់** ។

## ១.២. សាវតានៃការវិវត្តស្ថាប័ននិយ័តករធានារ៉ាប់រង

ចាប់ពីចុងទស្សវត្សរ៍ទី៨០ ជាដំណាក់កាលដំបូងសម្រាប់ការកកើតឡើងវិញនៃវិស័យធានារ៉ាប់រងដែលស្ថិតនៅក្នុងអន្តរកាលនៃការចាប់ផ្តើមប្រកាន់យកសេដ្ឋកិច្ចទីផ្សារសេរីរបស់កម្ពុជា តាមរយៈការផ្លាស់ប្តូរពាណិជ្ជកម្មជាមួយបណ្តាប្រទេសលើសកលលោក។ ការធ្វើពាណិជ្ជកម្មអន្តរជាតិនេះ ជាកត្តាតម្រូវឱ្យមានការធានារ៉ាប់រងលើការដឹកជញ្ជូនទំនិញ ជាពិសេសទំនិញនាំចូលមកកម្ពុជា។ ជាកិច្ចសម្រួលពាណិជ្ជកម្ម រដ្ឋាភិបាលនាសម័យនោះបានបង្កើតក្រុមហ៊ុនរដ្ឋមួយឈ្មោះថា **ក្រុមហ៊ុនជាតិធានារ៉ាប់រងកម្ពុជា (កាមិនកូ)** ជាផ្លូវការនៅឆ្នាំ១៩៩០ ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានចាប់ផ្តើមប្រតិបត្តិការក្នុងទីផ្សារកម្ពុជានៅពាក់កណ្តាលខែមិថុនា ឆ្នាំ១៩៩៣។ ក្រុមហ៊ុនកាមិនកូ បានដើរតួនាទី

ជាប្រតិបត្តិករផងនិងជានិយ័តករផង ដោយមានក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងឯកជនចំនួន ៣ ដែលដើរតួនាទីជាភ្នាក់ងារលក់ផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុនកាមិនកូ។

ផ្អែកតាមភាពចាំបាច់ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការធានារ៉ាប់រងដែលត្រូវបានអនុម័តដោយសភាជាតិ និងត្រូវបានឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០។ ច្បាប់នេះបានកំណត់គោលដៅដោយធានាឱ្យបាននូវប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចប្រតិបត្តិការធានារ៉ាប់រង និងការលើកកម្ពស់ការការពារសិទ្ធិរបស់ភាគីនានា ចំពោះការធានារ៉ាប់រង ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យធានារ៉ាប់រង។ លើសពីនេះ ច្បាប់ស្ដីពីការធានារ៉ាប់រងបានផ្ដល់សមត្ថកិច្ចក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យវិស័យធានារ៉ាប់រងជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យធានារ៉ាប់រងនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ជាសេនាធិការ។

ឆ្លើយតបនឹងតម្រូវការជាក់ស្ដែងក៏ដូចជា ការរីកចម្រើនយ៉ាងរហ័ស នៃវិស័យធានារ៉ាប់រង រាជរដ្ឋាភិបាល ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជានិយ័តករធានារ៉ាប់រងកម្ពុជា បានបង្កើនសមត្ថភាពគ្រប់គ្រងវិស័យធានារ៉ាប់រង ពីការិយាល័យធានារ៉ាប់រងនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទៅជានាយកដ្ឋានធានារ៉ាប់រងនិងសោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាឆ្នាំ២០១៣។ នាយកដ្ឋានធានារ៉ាប់រងនិងសោធន មានបួនការិយាល័យសំខាន់ៗគឺ÷ ការិយាល័យត្រួតពិនិត្យ ការិយាល័យអភិវឌ្ឍន៍ទីផ្សារ ការិយាល័យនីតិកម្មនិងផ្សះផ្សាវិវាទ និងការិយាល័យសោធន។

ស្របតាមទិសដៅនៃគោលនយោបាយសំខាន់ៗ របស់រាជរដ្ឋាភិបាលមានដូចជា "**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**" "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**" និង "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥**" រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្ដីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ដែលត្រូវបានដាក់ឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។ ច្បាប់នេះ បានបង្កើត **និយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.)** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** ដោយមានតួនាទីធ្វើនិយ័តកម្មវិស័យធានារ៉ាប់រងកម្ពុជា ជំនួសឱ្យនាយកដ្ឋានធានារ៉ាប់រងនិងសោធននៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងការបំពេញតួនាទីនេះ និយ័តករធានារ៉ាប់រងកម្ពុជាបានរៀបចំនូវ "**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០**" ដែលជាឯកសារសម្រាប់តម្រង់ទិសក្នុងការអភិវឌ្ឍទីផ្សារធានារ៉ាប់រងកម្ពុជា និងបានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១។ តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជាខាងលើ ការងារអាទិភាពដែលបានដាក់

ចេញត្រូវបានកំណត់យ៉ាងច្បាស់ដោយសង្កត់ធ្ងន់លើ "**ការអភិវឌ្ឍស្ថាប័ននិយ័តករធានារ៉ាប់រងនិងហេដ្ឋារចនាសម្ព័ន្ធនៃវិស័យធានារ៉ាប់រង**"។

### ១.៣. រចនាសម្ព័ន្ធបច្ចុប្បន្ននៃនិយ័តករធានារ៉ាប់រងកម្ពុជា

យោងតាមច្បាប់ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" **ន.ធ.ក.** គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពក្រោមឱវាទផ្សេងទៀតរបស់ **អ.ស.ហ.** ក្នុងនោះមានដូចជា អគ្គលេខាធិការដ្ឋាន និយ័តករមូលបត្រកម្ពុជា និយ័តករសន្តិសុខសង្គម និយ័តករបរធនបាលកិច្ច និយ័តករគណនេយ្យនិងសវនកម្ម និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និងអង្គភាពសវនកម្មផ្ទៃក្នុង។ **ន.ធ.ក.** ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារជាសេនាធិការមួយនៃ **អ.ស.ហ.**ដែលមានតួនាទីគ្រប់គ្រងត្រួតពិនិត្យ និងអភិវឌ្ឍវិស័យធានារ៉ាប់រង។ លើសពីនេះ យោងតាម "អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" និង "ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពក្រោមឱវាទរបស់និយ័តករធានារ៉ាប់រងកម្ពុជា" អង្គការលេខរបស់ និយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបានកំណត់ដូចខាងក្រោម÷




<u>រូបភាពទី១</u>÷ អង្គការលេខនៃនិយ័តករធានារ៉ាប់រងកម្ពុជា

**និមិត្តសញ្ញារបស់និយ័តករធានារ៉ាប់រងកម្ពុជា**

- ***រូបហង្សពណ៌មាស៖*** តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុដែលជាអ្នកគ្រប់គ្រង ត្រួតពិនិត្យប្រតិបត្តិការធានារ៉ាប់រងនិងសោធនឯកជន និងធានាឱ្យដំណើរការទីផ្សារធានារ៉ាប់រងនិងសោធនឯកជនប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- ***រូបខែលនិងអក្សរ ន.ធ.ក.៖*** តំណាងឱ្យការការពារលើការបាត់បង់ផ្នែកហិរញ្ញវត្ថុ នៅពេលដែលមានហានិភ័យកើតឡើង (ធានារ៉ាប់រង) និងតំណាងឱ្យនិយ័តករធានារ៉ាប់រងកម្ពុជា
- ***រូបហង្សពណ៌មាសឈរលើខែល៖*** បង្ហាញពីដំណើរការនៃទីផ្សារធានារ៉ាប់រងនិងសោធនឯកជន ស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់និយ័តករធានារ៉ាប់រងកម្ពុជា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងយុត្តិធម៌
- ***រូបស្លឹកឈើ៖*** លទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់ ធានារ៉ាប់រងនិងសោធនឯកជន ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

## ១.៤. សមិទ្ធផលសម្រេចបាន

ក្នុងរយៈពេលជាង ២០ឆ្នាំកន្លងមកនេះ ចាប់តាំងពីឆ្នាំ ២០០០ មក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជានិយ័តករនៃវិស័យធានារ៉ាប់រងមានសមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រងនៅកម្ពុជា សម្រេចបាននូវសមិទ្ធផលយ៉ាងច្រើនទាំងក្នុងក្របខណ្ឌបញ្ញត្តិកម្ម ក្របខណ្ឌទីផ្សារធានារ៉ាប់រង និងក្របខណ្ឌបច្ចេកទេស ដែលជាការកំលាំងស្នូលជំរុញការរីកចម្រើននៃវិស័យធានារ៉ាប់រងកម្ពុជា។

ក្នុងក្របខណ្ឌបញ្ញត្តិកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជានិយ័តករធានារ៉ាប់រង បានរៀបចំច្បាប់ស្តីពីការធានារ៉ាប់រង ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្តនៅឆ្នាំ២០០០ ជាមួយនិងអនុក្រឹត្យស្តីពីការធានារ៉ាប់រង ត្រូវបានអនុម័តដាក់ឱ្យអនុវត្តនៅឆ្នាំ២០០១។ បទប្បញ្ញត្តិចំនួន ១៦ ពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង ការគ្រប់គ្រងហិរញ្ញវត្ថុនិងការគ្រប់គ្រងប្រតិបត្តិការទីផ្សារត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់។ បន្ថែមលើនេះ ដើម្បីឆ្លើយតបនឹងការរីកចម្រើនយ៉ាងឆាប់រហ័សនៃវិស័យធានារ៉ាប់រងកម្ពុជា និងការវិវត្តថ្មីៗនៃទីផ្សារធានារ៉ាប់រងក្នុងតំបន់ ក៏ដូចជាលើសកលលោក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំច្បាប់ស្តីពីការធានារ៉ាប់រងថ្មី ដែលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០១៤ ដើម្បីជំនួសច្បាប់ស្តីពីការធានារ៉ាប់រងឆ្នាំ២០០០។

ជាមួយនឹងសមិទ្ធផលសម្រេចបានក្នុងក្របខណ្ឌបញ្ញត្តិកម្ម ការអភិវឌ្ឍទីផ្សារធានារ៉ាប់រងកម្ពុជាក៏ទទួលបានផ្លែផ្កាគួរឱ្យកត់សម្គាល់ផងដែរដែលចែកចេញជាដំណាក់កាលធំៗពីរ គឺចាប់ពីឆ្នាំ២០០០ រហូត

ដល់ឆ្នាំ២០១១ ទីផ្សារធានារ៉ាប់រងកម្ពុជា មានតែក្រុមហ៊ុនធានារ៉ាប់រងទូទៅប៉ុណ្ណោះ លក់ផលិតផលធានារ៉ាប់រងទូទៅ ដែលជាផលិតផលធានារ៉ាប់រងមានលក្ខណៈការពារសុទ្ធសាធ (Pure Protection) និងមានរយៈពេលខ្លី។ រហូតដល់ឆ្នាំ២០១២ ដោយបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត លក់ផលិតផលធានារ៉ាប់រងអាយុជីវិត ដែលមានលក្ខណៈទាំងការពារនិងសន្សំ និងមានរយៈពេលវែង ដើម្បីបម្រើដល់ប្រជាពលរដ្ឋដែលមានចំណូលមធ្យម និងបានផ្តល់អាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចលក់ផលិតផលធានារ៉ាប់រងខ្នាតតូច ដែលមានបុព្វលាភទាប ដើម្បីបម្រើជាពិសេសដល់ប្រជាពលរដ្ឋដែលមានចំណូលទាបនៅតាមជនបទ។ បច្ចុប្បន្ន មានក្រុមហ៊ុនធានារ៉ាប់រងទូទៅមានចំនួន១៨, ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតមានចំនួន១៤, ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចមានចំនួន៦ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន១ កំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះមានក្រុមហ៊ុនបរទេសចំនួន២៣, ក្រុមហ៊ុនក្នុងស្រុកចំនួន១៥ និងក្រុមហ៊ុនចំរុះរដ្ឋចំនួន២។ ទីផ្សារធានារ៉ាប់រងកម្ពុជា មានទ្រព្យសកម្មចំនួនប្រមាណ ៨៤៥ លានដុល្លារអាមេរិក និងមូលនិធិភាគហ៊ុនិកប្រមាណ ៣៧៨ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២១។

ដោយឡែកក្នុងក្របខណ្ឌបច្ចេកទេសក្នុងការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មធានារ៉ាប់រង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏បានអនុវត្តយន្តការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន (Prudential Supervision) តាមវិធីសាស្ត្រត្រួតពិនិត្យផ្អែកលើបទប្បញ្ញត្តិ (Rule-Based Supervision) ដោយតាមដាននិងវាយតម្លៃហានិភ័យរបស់ក្រុមហ៊ុនធានារ៉ាប់រង ផ្តោតសំខាន់លើផ្នែកហិរញ្ញវត្ថុ និងកិច្ចដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនដែលរួមមាន ការបង្កើតនិងរំលាយក្រុមហ៊ុន ការគ្រប់គ្រងនិងអភិបាលកិច្ចក្រុមហ៊ុន ការរៀបចំអនុវត្តស្តង់ដារគណនេយ្យនិងសវនកម្ម ការរៀបចំផែនការវិនិយោគ ការរៀបចំកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត និងការរក្សាដើមទុនតម្រូវនិងកម្រិតសាធនភាពរបស់ក្រុមហ៊ុន ជាដើម។

ជារួម ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីផ្សារធានារ៉ាប់រងបានរួមភាគទានក្នុងសេដ្ឋកិច្ច (Insurance Penetration Rate) ជាអត្រាប្រមាណ ១.១០% ជាមួយដង់ស៊ីតេធានារ៉ាប់រង (Insurance Density) ប្រមាណ ១៨.៦១ ដុល្លារអាមេរិកក្នុងឆ្នាំ២០២១។

ទោះបីជាសមិទ្ធផលគួរឱ្យកត់សម្គាល់មួយចំនួនត្រូវបានសម្រេចរួចមកហើយក្តី ក៏ដំណើរការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាកំពុងស្ថិតក្នុងរបត់មួយថ្មី ដែលទាមទារឱ្យមានការគិតគូរជាចាំបាច់

ជាពិសេសលើការអភិវឌ្ឍស្ថាប័ននិយ័តករធានារ៉ាប់រងកម្ពុជា ដើម្បីកែលម្អចំណុចខ្វះខាត សំដៅពន្លឿនការរួមចំណែកជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឱ្យរីកចម្រើនប្រកបដោយចីរភាពយ៉ាងពិតប្រាកដ។

## ផ្នែកទី ២÷ ទស្សនវិស័យសម្រាប់អភិវឌ្ឍស្ថាប័ន

ភាពមិនច្បាស់លាស់នៃវិបត្តិជាសកលកើតចេញពីជម្ងឺកូវីដ-១៩ និងការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលដែលកំពុងកើតឡើងនាពេលបច្ចុប្បន្ននេះ បានបង្កើតជាបរិយាកាសទាំងក្នុងនិងក្រៅ ដែលលាយឡំទៅដោយចំណុចខ្លាំង ខ្សោយ ការគំរាមគំហែង និងកាលានុវត្តភាព ដែលអាចយកធ្វើជាមូលដ្ឋានសម្រាប់ពង្រឹងសមត្ថភាពស្ថាប័នឱ្យកាន់តែល្អប្រសើរ ដើម្បីសម្របខ្លួនទៅនឹងវិបត្តិ កាត់បន្ថយផលប៉ះពាល់ និងអាចកែប្រែចំណុចខ្សោយនិងការគំរាមគំហែង មកជាចំណុចខ្លាំងនិងជាកាលានុវត្តភាពជំនួសវិញ។ បន្ថែមពីនេះ ក៏នៅមានកត្តាសត្យានុម័តសំខាន់ៗមួយចំនួនដែលជាទស្សនវិស័យនិងមូលដ្ឋានគ្រឹះ សម្រាប់កំណត់ទិសដៅអនាគតនៃដំណើរការអភិវឌ្ឍស្ថាប័នផងដែរ។

### ២.១. ការវាយតម្លៃស្ថានភាពបច្ចុប្បន្ន (SWOT Analysis)

**ក. ភាពខ្លាំង**

- ស្ថាប័ននិយ័តករដែលទើបបង្កើតថ្មី និងមានរចនាសម្ព័ន្ធច្បាស់លាស់
- ចក្ខុវិស័យវែងឆ្ងាយនិងភាពជាអ្នកដឹកនាំរបស់ **អ.ស.ហ.** ក៏ដូចជា **ន.ធ.ក.** ប្រកបដោយភាពប្រាកដនិយម
- ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** មានឆន្ទៈនិងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការបំពេញការងារទៅតាមតួនាទីនិងភារកិច្ច
- ការជ្រើសរើស ការតែងតាំងនិងការលើកទឹកចិត្តមន្ត្រី **ន.ធ.ក.** ប្រកបដោយគណនេយ្យភាពនិងតម្លាភាព ដោយផ្តោតចម្បងលើសមត្ថភាព គុណវុឌ្ឍិ ឆន្ទៈនិងសមភាពយេនឌ័រ។

**ខ. ភាពខ្សោយ**

- ចំនួនមន្ត្រីនិងថ្នាក់ដឹកនាំ នៅមិនទាន់ឆ្លើយតបនឹងទំហំការងារជាក់ស្តែងរបស់ **ន.ធ.ក.**
- ទីកន្លែងសម្រាប់បំពេញការងារនៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង
- ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់គាំទ្រកិច្ចដំណើរការរបស់ **ន.ធ.ក.** នៅមានកម្រិត
- ប្រព័ន្ធលើកទឹកចិត្តនៅមិនទាន់ធានាបាននូវភាពប្រកួតប្រជែងជាមួយវិស័យឯកជន ដើម្បីទាក់ទាញធនធានដែលមានជំនាញខ្ពស់។

**គ. កាលានុវត្តភាព**

- កិច្ចសហប្រតិបត្តិការរវាងស្ថាប័ននិយ័តករទាំងក្នុងក្របខណ្ឌតំបន់និងអន្តរជាតិ
- ការចូលរួមសមាហរណកម្មនិងសេរីភាវូបនីយកម្មវិស័យហិរញ្ញវត្ថុក្នុងតំបន់និងអន្តរជាតិ
- កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធដើម្បីពង្រឹងសមត្ថភាពជំនាញបច្ចេកទេសរបស់ **ន.ធ.ក.**
- ការពង្រឹងភាពជាដៃគូរវាងនិយ័តករ និងប្រតិបត្តិករធានារ៉ាប់រង
- ការរីកចម្រើននៃបច្ចេកវិទ្យាឌីជីថល ជាពិសេសបច្ចេកវិទ្យាធានារ៉ាប់រងសម្រាប់គាំទ្រដល់ប្រសិទ្ធភាពនៃការបំពេញការងាររបស់ **ន.ធ.ក.** ។

**ឃ. ការគំរាមកំហែង**

- ធនធានហិរញ្ញវត្ថុរបស់ **ន.ធ.ក.** មានកម្រិតសម្រាប់វិនិយោគ លើប្រព័ន្ធបច្ចេកវិទ្យាឌីជីថលដែលមានការវិវត្តយ៉ាងឆាប់រហ័សក្នុងវិស័យធានារ៉ាប់រង
- ការយល់ដឹងរបស់សាធារណជន អំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រង និង តួនាទីនិងភារកិច្ចរបស់និយ័តករធានារ៉ាប់រងនៅមានកម្រិត
- ភាពមិនប្រាកដប្រជានិងការបន្តអូសបន្លាយនៃវិបត្តិកូវីដ-១៩ បណ្តាលមកពីវីរុសបម្លែងខ្លួនថ្មីៗ ដែលជាឧបសគ្គរាំងដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ស្ថាប័នឱ្យបានពេញលេញ។

## ២.២. កត្តាកំណត់ទិសដៅអភិវឌ្ឍស្ថាប័ន

យោងតាមការវិភាគខាងលើនិងផ្អែកតាមបរិការណ៍បច្ចុប្បន្ន មានកត្តាសត្យានុម័តមួយចំនួនដែលជាទស្សនវិស័យនិងមូលដ្ឋានគ្រឹះ សម្រាប់កំណត់ទិសដៅអនាគតនៃដំណើរការអភិវឌ្ឍស្ថាប័ន **ន.ធ.ក.**។ កត្តាសត្យានុម័តទាំងនោះមានដូចខាងក្រោម÷

**ទី១. ន.ធ.ក. ស្ថិតក្នុងដំណាក់កាលដំបូងនៃការប្រែក្លាយជាស្ថាប័ននិយ័តកម្មឯករាជ្យ÷** កត្តានេះទាមទារឱ្យ **ន.ធ.ក.** ត្រូវកំណត់នូវទិសដៅជាក់លាក់នៃការពង្រឹងមុខងារ និងភារកិច្ចស្ថាប័នរបស់ខ្លួន ក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យសកម្មភាពអាជីវកម្មធានារ៉ាប់រង និងសោធនឯកជន ជាពិសេសលើការរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាព និងច្បាស់លាស់។

**ទី២. គម្លាតរវាងសមត្ថភាពស្ថាប័ន និងទំហំនៃការងារជាក់ស្តែង÷** ការអនុវត្តផែនការសកម្មភាព ព្រមទាំងការតាមដាននិងវាយតម្លៃ អាចមិនត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ ស្របទៅនឹងគោលបំណងរបស់ផែនការយុទ្ធសាស្ត្រ ដែលទាំងនេះបណ្តាលមកពីកត្តាធនធានទ្រទ្រង់ស្ថាប័នបច្ចុប្បន្ន

នៅមានកម្រិតទាំងបរិមាណ និងគុណភាព។ ដើម្បីឆ្លើយតបនឹងបញ្ហាខាងលើនេះ **ន.ធ.ក.** ត្រូវពង្រឹងបន្ថែមលើសមត្ថភាពស្ថាប័ន ដោយផ្តោតកិច្ចខិតខំប្រឹងប្រែងលើការកែលម្អរចនាសម្ព័ន្ធគ្រប់គ្រង អភិបាលកិច្ចល្អ ធនធានមនុស្ស និងបរិស្ថាននិងលក្ខខណ្ឌការងារ។

**ទី៣. ការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដែលជាឧបករណ៍គាំទ្រដ៏សំខាន់ក្នុងការអភិវឌ្ឍស្ថាប័ន÷** កត្តានេះអាចអនុញ្ញាតឱ្យ **ន.ធ.ក.** ទាញយកផលប្រយោជន៍ជាអតិបរមាពីការរីកចម្រើននៃប្រព័ន្ធបច្ចេកវិទ្យាទាំងនេះ ដើម្បីបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារ ស្របតាមបរិការណ៍សេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលទាមទារឱ្យមានការពង្រឹងសមត្ថភាពស្ថាប័នជាបន្តបន្ទាប់។

**ទី៤. ការសម្របខ្លួននិងការកាត់បន្ថយផលប៉ះពាល់នៃវិបត្តិ÷** បទពិសោធន៍ពីការអនុវត្តកម្មវិធីកំណែទម្រង់ស្ថាប័ននិងការធ្វើបច្ចុប្បន្នភាពគោលនយោបាយ ក្នុងនិងក្រោយពេលមានវិបត្តិហិរញ្ញវត្ថុសកល និងការបន្តអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ កន្លងមក គឺជាឧត្តមានុវត្តល្អៗសម្រាប់ស្ថាប័នធ្វើការសម្របខ្លួន និងត្រៀមខ្លួនជាមុនបានល្អប្រសើរ។ **ន.ធ.ក.** ត្រូវបន្តពង្រឹងយន្តការសម្របសម្រួលចែករំលែកព័ត៌មាននិងទិន្នន័យ វិធានការឆ្លើយតបក្នុងនិងក្រោយពេលមានវិបត្តិ ជាពិសេសតាមរយៈយន្តការភាពជាដៃគូរវាងនិយ័តករធានារ៉ាប់រងកម្ពុជា សមាគមធានារ៉ាប់រងកម្ពុជា និងគ្រឹះស្ថានធានារ៉ាប់រង ដើម្បីបង្កើនទំនុកចិត្ត និងកាត់បន្ថយផលប៉ះពាល់លើវិស័យធានារ៉ាប់រង។

**ទី៥. ការសម្របខ្លួនទៅនឹងនិន្នាការសេរីភាវូបនីយកម្ម នៃវិស័យធានារ៉ាប់រងទាំងក្នុងតំបន់ និងអន្តរជាតិ÷** ដំណើរវិវត្តនៃនិន្នាការសេរីភាវូបនីយកម្មតំបន់និងពិភពលោក ជាពិសេសការធ្វើអនុលោមភាពតាមគោលការណ៍គ្រឹះធានារ៉ាប់រង (ICPs) របស់សមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (IAIS) បាននិងកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដែលទាមទារឱ្យមានការតាមដាន វាយតម្លៃ និងពិនិត្យឡើងវិញជាប្រចាំលើរចនាសម្ព័ន្ធគ្រប់គ្រង មុខងារ និងភារកិច្ចរបស់ស្ថាប័ន ដើម្បីឆ្លើយតបទៅនឹងដំណើរវិវត្តទាំងនេះទាន់ពេលវេលា ប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់។

## ផ្នែកទី ៣ ÷ ចក្ខុវិស័យ គោលបំណង និងគោលដៅ

### ៣.១. ចក្ខុវិស័យ

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ បានកំណត់ចក្ខុវិស័យជារួម÷ “**ធានាបាននូវភាពរឹងមាំ និងឧត្តមភាពប្រកួតប្រជែង ប្រកបដោយចីរភាពរបស់គ្រឹះស្ថានធានារ៉ាប់រងទាំងអស់ ដើម្បីបម្រើដល់ពលរដ្ឋកម្ពុជាគ្រប់រូប និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។**”

ក្នុងក្របខណ្ឌអភិវឌ្ឍន៍ស្ថាប័ន **ន.ធ.ក.** មានចក្ខុវិស័យ÷ “**ប្រែក្លាយជាស្ថាប័ននិយ័តកម្មឯករាជ្យមួយដែលមានសមត្ថភាព ប្រកបដោយវិជ្ជាជីវៈ និងទទួលបានជំនឿទុកចិត្តខ្ពស់ពីសំណាក់មហាជន ដើម្បី**

**ឆ្លើយតបទៅនឹងកំណើនតម្រូវការ និងការរីកលូតលាស់យ៉ាងឆាប់រហ័សនៃវិស័យធានារ៉ាប់រងដែលប្រកបដោយសក្តានុពលនិងកាលានុវត្តភាព សំដៅជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ។"**

### ៣.២. គោលបំណង និងគោលដៅ

ផែនការនេះមានគោលបំណង ផ្តល់នូវក្របខណ្ឌអភិវឌ្ឍន៍ស្ថាប័នមួយច្បាស់លាស់ដែលដើរតួនាទីជាត្រីវិស័យចង្អុលផ្លូវនិងតម្រែតម្រង់សកម្មភាពការងារក្នុងរយៈពេលមធ្យម សម្រាប់ពង្រឹងសមត្ថភាពនិងមុខងារស្ថាប័ន **ន.ធ.ក.** ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជា។

ផ្អែកលើគោលបំណងខាងលើនេះ "ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា" មានគោលដៅសំខាន់ៗ ដូចខាងក្រោម÷

- ពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីធានាបាននូវប្រសិទ្ធភាពការងារនិងទំនួលខុសត្រូវលើមុខងារនិងតួនាទីស្ថាប័នដូចមានចែងក្នុងច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ តាមរយៈការលើកកម្ពស់រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន, ជំរុញអភិបាលកិច្ច, ជំរុញការអភិវឌ្ឍធនធានមនុស្ស និងកែលម្អបរិស្ថាន និងលក្ខខណ្ឌការងារ
- ពង្រឹងការតភ្ជាប់ជាមួយទីផ្សារធានារ៉ាប់រង ទាំងផ្នែកទន់និងផ្នែករឹង ដើម្បីធានាបាននូវការអភិវឌ្ឍទីផ្សារប្រកបដោយចីរភាព តាមរយៈការបង្កើតភាពជាដៃគូច្បាស់លាស់ជាមួយប្រតិបត្តិករធានារ៉ាប់រង, ផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង និងបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង និងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារធានារ៉ាប់រង (InsurTech-RegTech and SupTech)
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ស្ថាប័នឯកជន និងដៃគូអភិវឌ្ឍពាក់ព័ន្ធ។

## ផ្នែកទី ៤ ÷ ផែនការសកម្មភាព

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥ **ន.ធ.ក.** បានកំណត់ក្របខណ្ឌយុទ្ធសាស្ត្រ ដោយឈរលើសសរស្តម្ភសំខាន់ៗចំនួន ០៣ (3Cs) និងគោលការណ៍ SMART ក្នុងការរៀបចំសកម្មភាពការងារដូចខាងក្រោម÷

### ៤.១. ក្របខណ្ឌយុទ្ធសាស្ត្រ

សសរស្តម្ភសំខាន់ៗមានចំនួន ០៣ (**ឬហៅថា 3Cs**) ដែលជាក្របខណ្ឌយុទ្ធសាស្ត្រនៃការរៀបចំសកម្មភាពការងារ រួមមាន÷ **សមត្ថភាពស្ថាប័ន (Capacity), ការតភ្ជាប់ (Connectivity) និងកិច្ចសហប្រតិបត្តិការ (Cooperation)**។

- **សសរស្តម្ភទី១ សមត្ថភាពស្ថាប័ន** (Capacity)÷ ផ្តោតជាចម្បងលើសមត្ថភាពរបស់ស្ថាប័នរួមមាន រចនាសម្ព័ន្ធស្ថាប័ន អភិបាលកិច្ច ធនធានមនុស្ស ព្រមទាំងបរិស្ថាននិងលក្ខខណ្ឌការងារ។
- **សសរស្តម្ភទី២ ការតភ្ជាប់** (Connectivity)÷ ផ្តោតជាចម្បងលើការតភ្ជាប់របស់ស្ថាប័នរួមមានទាំងការតភ្ជាប់ផ្នែករឹង និងការតភ្ជាប់ផ្នែកទន់។
- **សសរស្តម្ភទី៣ កិច្ចសហប្រតិបត្តិការ** (Cooperation)÷ ផ្តោតជាចម្បងលើការពង្រឹងកិច្ចសហប្រតិបត្តិការទាំងក្របខណ្ឌក្នុងប្រទេស និងអន្តរជាតិ។




**<u>រូបភាពទី២÷</u>** គំនូសបំព្រួញនៃសសរស្តម្ភទាំងបី

## ៤.២. គោលការណ៍នៃការរៀបចំសកម្មភាពការងារ

ដើម្បីសម្រួលដល់ការអនុវត្តសកម្មភាពការងារឱ្យមានប្រសិទ្ធភាព **ន.ធ.ក.** បានរៀបចំសកម្មភាពការងារដោយប្រកាន់យកគោលការណ៍សំខាន់ៗចំនួនប្រាំ (ឬហៅថា SMART)។

- **ភាពជាក់លាក់ (Specific)**÷ មានគោលដៅជាក់លាក់លើសកម្មភាពការងារសម្រាប់កែលម្អណាមួយ
- **អាចវាស់វែងបាន (Measurable)**÷ អាចកំណត់បានជាបរិមាណដើម្បីសម្គាល់វឌ្ឍនភាព
- **អាចសម្រេចបាន (Achievable)**÷ មានទំហំឬលទ្ធភាពសមល្មមអាចសម្រេចបាន
- **ភាពជាប់ទាក់ទង (Relevant)**÷ មានការជាប់ទាក់ទងទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ ឬផែនការ
- **មានពេលវេលាកំណត់ (Time-bound)**÷ មានការដាក់ពេលវេលាកំណត់ជាក់លាក់សម្រាប់ការអនុវត្ត។




**<u>រូបភាពទី៣</u>**÷ គំនូសបំព្រួញនៃគោលការណ៍ SMART

### ៤.៣. សមត្ថភាពការងារ

#### ៤.៣.១. សមត្ថភាពស្ថាប័ន (Capacity)

តាមរយៈការធ្វើវិចារណកម្មតួនាទីនិងភារកិច្ចរបស់និយ័តករ **ន.ធ.ក.** ត្រូវធ្វើការកែសម្រួលនិងរៀបចំថ្មី នូវបទប្បញ្ញត្តិនិងវិធានមួយចំនួនបន្ថែមទៀតពាក់ព័ន្ធនឹងរចនាសម្ព័ន្ធស្ថាប័ន អភិបាលកិច្ច ធនធានមនុស្ស និងបរិស្ថាននិងលក្ខខណ្ឌការងារ សំដៅធានាបាននូវសង្គតិភាព ការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ខ្លួន។

**ក. រចនាសម្ព័ន្ធស្ថាប័ន**

ស្ថាប័ននិយ័តករធានារ៉ាប់រងកម្ពុជាត្រូវកំណត់មុខងារឱ្យបានច្បាស់លាស់ ដើម្បីឆ្លើយតបនឹងទំហំការងារជាក់ស្តែងក្នុងគោលបំណងធានាបាននូវការអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជាប្រកបដោយចីរភាព។ យ៉ាងណាមិញ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០២១ បានកំណត់រចនាសម្ព័ន្ធស្ថាប័នច្បាស់លាស់របស់ **ន.ធ.ក.** **គឺ ជាសេនាធិការរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានតួនាទីគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យធានារ៉ាប់រង។ បន្ថែមលើនេះ **ន.ធ.ក.** មានផែនការមួយចំនួនទៀតដូចខាងក្រោម÷

- រៀបចំបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធស្ថាប័ននិយ័តករធានារ៉ាប់រងកម្ពុជា (អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទ **ន.ធ.ក.** (ប្រកាសលេខ០០៥ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករធានារ៉ាប់រងកម្ពុជា បានដាក់ឱ្យអនុវត្តរួចហើយ)
- សិក្សាវិភាគមុខងារស្ថាប័ននិយ័តករដើម្បីកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន **ន.ធ.ក.** ផ្អែកលើភាពចាំបាច់។

**ខ. អភិបាលកិច្ច**

អភិបាលកិច្ចគឺជាដំណើរការនៃការដឹកនាំ និងគ្រប់គ្រងស្ថាប័នមួយដោយផ្អែកលើច្បាប់និងបទប្បញ្ញត្តិជាធរមាន។ **ន.ធ.ក.** មានគោលដៅធានាបាននូវអភិបាលកិច្ចល្អដែលមានតួនាទីចម្បងក្នុងការសម្រេចបាននូវភាពជោគជ័យរបស់ស្ថាប័ន។ ក្នុងការដឹកនាំនិងគ្រប់គ្រង **ន.ធ.ក.** ការតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **ន.ធ.ក.** ត្រូវរៀបចំឡើងដើម្បីបែងចែកតួនាទីនិងភារកិច្ចក្នុងការ

ទទួលខុសត្រូវ ទាំងក្នុងកម្រិតនាយកដ្ឋាន កម្រិតការិយាល័យ និងកម្រិតមន្ត្រីជំនាញ ក្នុងគោលដៅធានានូវការប្រព្រឹត្តទៅរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាពខ្ពស់។ ទាក់ទងនឹងការងារនេះ **ន.ធ.ក.** មានផែនការមួយចំនួនដូចខាងក្រោម÷

- រៀបចំបទប្បញ្ញត្តិតែងតាំងថ្នាក់ដឹកនាំអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អនុក្រឹត្យលេខ ២១០ អនក្រ.តត ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបទប្បញ្ញត្តិតែងតាំងអគ្គនាយកនៃ **ន.ធ.ក.** (ព្រះរាជក្រឹត្យលេខ នស/រកត/០២២១/១៤៤ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការតែងតាំងមុខតំណែងនិងផ្តល់ឋានៈដល់មន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបទប្បញ្ញត្តិតែងតាំងថ្នាក់ដឹកនាំនៃ **ន.ធ.ក.** (អនុក្រឹត្យលេខ២៨៨ អនក្រ.តត ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០២១ និងអនុក្រឹត្យលេខ៣៦២ អនក្រ.តត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការតែងតាំងមន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយមានការតែងតាំងអគ្គនាយករង និងប្រធាននាយកដ្ឋាននៃនិយ័តករធានារ៉ាប់រងកម្ពុជា បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបទប្បញ្ញត្តិតែងតាំងថ្នាក់ដឹកនាំការិយាល័យនៃ **ន.ធ.ក.** (ប្រកាសលេខ០១២ អ.ស.ហ.ប្រក ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការតែងតាំងមន្ត្រីរាជការនៃនិយ័តករធានារ៉ាប់រងកម្ពុជា បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ **ន.ធ.ក.** (សេចក្តីសម្រេចលេខ០០១ ន.ធ.ក./សរ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ២០២២ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំនៃនិយ័តករធានារ៉ាប់រងកម្ពុជា បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំចាត់តាំងមន្ត្រីឱ្យបំពេញការងារតាមនាយកដ្ឋាន នៃ **ន.ធ.ក.** (លិខិតបង្គាប់ការលេខ០០២ ន.ធ.ក./សរ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបទប្បញ្ញត្តិទទួលស្គាល់មន្ត្រីលក្ខន្តិកៈ (ប្រកាសលេខ០០៤ អ.ស.ហ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ឱ្យចូលបម្រើការងារនៅនិយ័តករធានារ៉ាប់រងកម្ពុជា បានដាក់ឱ្យអនុវត្តរួចហើយ)

- រៀបចំបទប្បញ្ញត្តិបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់មន្ត្រី និងថ្នាក់ដឹកនាំ **ន.ធ.ក.** (សេចក្ដីសម្រេចលេខ០០១ អ.ស.ហ.ន.ធ.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់និយ័តករធានារ៉ាប់រងកម្ពុជា បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំបទបញ្ជាផ្ទៃក្នុងរបស់និយ័តករធានារ៉ាប់រងកម្ពុជា
- រៀបចំវិធានស្តីពីយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពការងារ
- រៀបចំវិធាន ស្តង់ដារ និងនីតិវិធីប្រតិបត្តិការរបស់ **ន.ធ.ក.**
- សិក្សានិងរៀបចំសំណើតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃ **ន.ធ.ក.** តាមភាពចាំបាច់នៃតួនាទីនិងភារកិច្ច។

### គ. ធនធានមនុស្ស

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តតួនាទីនិងភារកិច្ចរបស់ស្ថាប័ន កត្តាធនធានមនុស្សដើរតួនាទីចម្បងជាកម្លាំងអូសទាញទៅរកភាពជោគជ័យ។ យោងតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រង ២០២១-២០៣០ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ **ន.ធ.ក.** មានថ្នាក់ដឹកនាំនិងមន្ត្រីសរុបទាំងអស់ចំនួន ៥៦ រូប ដែលក្នុងនោះមានថ្នាក់ដឹកនាំនិយ័តករចំនួន ៣រូប ថ្នាក់ដឹកនាំនាយកដ្ឋានចំនួន ៥រូប ថ្នាក់ដឹកនាំការិយាល័យចំនួន ៦រូប និងមន្ត្រីជំនាញចំនួន ៤០រូប។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនឥតឈប់ឈរនៃទីផ្សារធានារ៉ាប់រង និងការកើនឡើងនៃទំហំការងាររបស់និយ័តករក្នុងការបំពេញតួនាទីគ្រប់គ្រងនិងត្រួតពិនិត្យទីផ្សារធានារ៉ាប់រង **ន.ធ.ក.** នឹងផ្តោតលើផែនការអភិវឌ្ឍន៍ធនធានមនុស្សដែលមានលក្ខណៈ ច្បាស់លាស់និងស៊ីជម្រៅ ដោយមានសមាសភាពចម្បងបីគឺ÷ (១)ការជ្រើសរើសមន្ត្រីថ្មីដើម្បីបំពេញមុខងារ របស់ស្ថាប័នដែលនៅខ្វះចន្លោះ (២)ការបណ្តុះបណ្តាលមន្ត្រីទាំងនៅក្នុងនិងក្រៅប្រទេសដើម្បីធានាបាននូវគុណភាពខ្ពស់ និង (៣)ការផ្តល់ការលើកទឹកចិត្តសមស្របដែលអាចប្រកួតប្រជែងក្នុងទីផ្សារការងារ។ ផែនការអភិវឌ្ឍន៍ធនធានមនុស្សរបស់ **ន.ធ.ក.** អាចអនុវត្តបានគឺត្រូវរៀបចំផែនការសកម្មភាពដូចខាងក្រោម÷

- រៀបចំជ្រើសរើសមន្ត្រី **ន.ធ.ក.** តាមផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៥ឆ្នាំ ចំនួន ១៤៥ រូប
- រៀបចំវគ្គបណ្តុះបណ្តាលជំនាញសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស
- រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស

- ចូលរួមរៀបចំបទប្បញ្ញត្តិកំណត់លក្ខន្តិកៈមន្ត្រីនៃ **អ.ស.ហ.** (ប្រកាសលេខ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** បានដាក់ឱ្យអនុវត្តរួចហើយ)
- ចូលរួមរៀបចំបទប្បញ្ញត្តិកំណត់ប្រាក់បៀវត្សសម្រាប់មន្ត្រីលក្ខន្តិកៈ (ប្រកាសលេខ០២២ អ.ស.ហ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការកំណត់ប្រាក់បៀវត្សសម្រាប់មន្ត្រីលក្ខន្តិកៈនិងមន្ត្រីជាប់កិច្ចសន្យារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រី **ន.ធ.ក.** សម្រាប់ដំឡើងឋានៈនិងឋានន្តរស័ក្តិ និងផ្តល់ប្រាក់ឧបត្ថម្ភ ប្រាក់រង្វាន់ លិខិតឬបណ្ណសរសើរ មេដាយការងារនិងអត្ថប្រយោជន៍ផ្សេងៗ។

### ឃ. បរិស្ថាននិងលក្ខខណ្ឌការងារ

បច្ចុប្បន្ន និយ័តករធានារ៉ាប់រងកម្ពុជាមានទីតាំងស្ថិតនៅជាន់ទី៦ នៃអគារលេខ ១៦៨ F លើបណ្តោយផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ផ្អែកតាមស្ថានភាពនិងទំហំជាក់ស្តែងនៃទីកន្លែងសម្រាប់បំពេញការងារ **ន.ធ.ក.** អាចផ្ទុកចំនួនមន្ត្រីនិងថ្នាក់ដឹកនាំ សមល្មមប្រមាណ ៦០រូប តែប៉ុណ្ណោះ។ លើសពីនេះ ដើម្បីជួយបង្កើនប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីនិងថ្នាក់ដឹកនាំ ប្រព័ន្ធគ្រប់គ្រងការងារ និងរំហូរឯកសារ ក៏គួរត្រូវបានធ្វើទំនើបកម្មតាមរយៈការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យាជាដំណាក់កាលៗ តាមលទ្ធភាពរបស់ស្ថាប័ន។ អាស្រ័យហេតុនេះ ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងទាំងនេះ **ន.ធ.ក.** ត្រូវមានផែនការសកម្មភាពដូចខាងក្រោម÷

- រៀបចំពង្រីកការិយាល័យធ្វើការរបស់ **ន.ធ.ក.** នៅអគាររដ្ឋបាលថ្មីបន្ថែម (មានផែនការសាងសង់រួចហើយ)
- រៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាល (Administration Information System-AIS) សម្រាប់គ្រប់គ្រងចលនាឯកសាររដ្ឋបាលផ្ទៃក្នុងរបស់និយ័តករនិងទទួលរាល់សំណើពីគ្រឹះស្ថានធានារ៉ាប់រង
- រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងវត្តមាន (Attendance Management Information System-AMIS) មន្ត្រីនៃ **ន.ធ.ក.**
- រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីនិងថ្នាក់ដឹកនាំដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម។

#### ៤.៣.២. ការតភ្ជាប់ (Connectivity)

ស្ថាប័នមួយ មានភាពចាំបាច់ក្នុងការពង្រឹងនិងពង្រីកការតភ្ជាប់របស់ខ្លួន ទៅនឹងមជ្ឈដ្ឋានខាងក្រៅដែលឆ្លុះបញ្ចាំងតាមរយៈកិច្ចខិតខំប្រឹងប្រែងនិងវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធ ទាំងផ្នែក

រឹងនិងផ្នែកទន់។ ក្នុងបរិការណ៍នេះ ការតភ្ជាប់របស់ស្ថាប័ន **ន.ធ.ក.** គឺសំដៅដល់ការតភ្ជាប់រវាង **ន.ធ.ក.** ទៅនឹងទីផ្សារធានារ៉ាប់រង ដែលរួមមាន សមាគមធានារ៉ាប់រង ប្រតិបត្តិករធានារ៉ាប់រង និងតួអង្គដទៃផ្សេងទៀតក្នុងទីផ្សារធានារ៉ាប់រង។

### ក. ការតភ្ជាប់ផ្នែករឹង

កាតព្វកិច្ចក្នុងការពង្រឹងនិងពង្រីកផ្នែករឹងនៃការតភ្ជាប់របស់ **ន.ធ.ក.** គឺត្រូវផ្ដោតលើការរៀបចំពង្រឹងសមត្ថភាពជំនាញនៅក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា ដូចជាបង្កើតវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈធានារ៉ាប់រង និងការបង្កើត “**សាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង**” ដោយមានផែនការសកម្មភាពការងារដូចខាងក្រោម៖

- រៀបចំកម្មវិធីបណ្ដុះបណ្ដាលវគ្គមូលដ្ឋាន និងឯកទេសអំពីវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអនុវត្តជាផ្លូវការ (បានដាក់ឱ្យអនុវត្តរួចហើយ)
- រៀបចំពង្រឹងកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា
- រៀបចំវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា
- សិក្សាសមិទ្ធិលទ្ធភាពស្ដីពី គម្រោងសាងសង់សាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង
- រៀបចំបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង។

### ខ. ការតភ្ជាប់ផ្នែកទន់

ជាមួយគ្នានេះដែរ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថលក៏អាចជួយ **ន.ធ.ក.** ក្នុងការពង្រឹងនិងពង្រីកផ្នែកទន់នៃការតភ្ជាប់ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការប្រមូលនិងគ្រប់គ្រងទិន្នន័យទីផ្សារ និងផ្ដល់សេវាជូនទីផ្សារធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពខ្ពស់ តាមរយៈផែនការវិនិយោគដូចខាងក្រោម៖

- រៀបចំប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យទីផ្សារធានារ៉ាប់រង (Insurance Data Collection and Management Information System-IDCMIS) សម្រាប់ប្រមូលនិងរក្សាទុកទិន្នន័យទីផ្សាររបស់គ្រឹះស្ថានធានារ៉ាប់រង (បានដាក់ឱ្យអនុវត្តដំណាក់កាលទី១ រួចហើយ)

- រៀបចំប្រព័ន្ធទទួលបណ្ដឹងធានារ៉ាប់រង (Insurance Complaint Management Information System-ICMIS) សម្រាប់ទទួលបណ្ដឹងធានារ៉ាប់រងតាមរយៈអនឡាញ និងរក្សាទុកទិន្នន័យបណ្ដឹង (បានដាក់ឱ្យអនុវត្តដំណាក់កាលទី១ រួចហើយ)
- រៀបចំប្រព័ន្ធវិភាគនិងផ្ដល់សញ្ញាមុន (Early Warning System) សម្រាប់វិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងផ្ដល់ការព្រមាន ដើម្បីចាត់វិធានការទាន់ពេលចំពោះក្រុមហ៊ុនដែលមានហានិភ័យខ្ពស់
- រៀបចំប្រព័ន្ធចុះបញ្ជីបុគ្គលភ្នាក់ងារធានារ៉ាប់រង (Insurance Agent Registration Management Information System-IARMIS) សម្រាប់គ្រប់គ្រង និងរក្សាទុកទិន្នន័យអំពីបុគ្គលភ្នាក់ងារធានារ៉ាប់រង
- រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រឹះស្ថានធានារ៉ាប់រង (Company Profile Management Information System-CPMIS)
- រៀបចំប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យអំពីផលិតផលធានារ៉ាប់រងយានយន្ត (MTPL Data Collection and Management Information System) សម្រាប់ដំណើរការគ្រប់គ្រងប្រព័ន្ធធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តជាកាតព្វកិច្ច ហើយប្រព័ន្ធនេះអាចពង្រីកបន្ថែមសម្រាប់គ្រប់គ្រងការធានារ៉ាប់រងជាកាតព្វកិច្ចដទៃទៀត
- រៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech)
- សិក្សាសមិទ្ធិលទ្ធផលក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា និងក្នុងក្របខណ្ឌសមាហរណកម្មតំបន់។

### ៤.៣.៣. កិច្ចសហប្រតិបត្តិការ (Cooperation)

#### ក. កិច្ចសហប្រតិបត្តិការក្នុងប្រទេស

ដើម្បីអភិវឌ្ឍស្ថាប័នរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ **ន.ធ.ក.** ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ននិងដៃគូពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសដោយសកម្ម ចូលរួមក្នុងគ្រប់វេទិកា យន្តការសម្របសម្រួល ភាពជាដៃគូ និងកិច្ចព្រមព្រៀងនានា សំដៅអភិវឌ្ឍវិស័យធានារ៉ាប់រងឱ្យកាន់តែមានចីរភាព។ ក្នុងរយៈពេល ៥ឆ្នាំនេះ **ន.ធ.ក.** ត្រូវ÷

- ពង្រឹងភាពជាដៃគូរវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងគ្រឹះស្ថានធានារ៉ាប់រង និងសមាគមធានារ៉ាប់រងដោយបង្កើតជាយន្តការទៀងទាត់ និងមានការរៀបចំរបៀបវារៈច្បាស់លាស់ សំដៅរួមចំណែកដោះស្រាយបញ្ហាប្រឈម និងកង្វល់ផ្សេងៗក្នុងវិស័យធានារ៉ាប់រង

- ជំរុញនិងលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនធានារ៉ាប់រងសម្រប-សម្រួលឱ្យសមាគមធានារ៉ាប់រងមានតំណាងក្នុងវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន និងវេទិកាផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលដែលធ្វើឡើងជារៀងរាល់ឆ្នាំ
- ពង្រឹងកិច្ចសហការជាមួយបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចតាមរយៈក្រុមការងារអន្តរក្រសួង
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.** និងនិយ័តករពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពអនុវត្តការងារ ការសម្របសម្រួល និងការចែករំលែកទិន្នន័យទីផ្សារធានារ៉ាប់រង និងទិន្នន័យសំខាន់ៗផ្សេងទៀត
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិកម្ពុជា ដើម្បីជំរុញប្រតិបត្តិការនៃការផ្ដល់សេវាធានារ៉ាប់រង តាមរយៈស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលហៅថា Bancassurance
- ពង្រឹងនិងពង្រីកកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងសមត្ថកិច្ចរួមរបស់ក្រសួងពាណិជ្ជកម្ម និងនិយ័តករធានារ៉ាប់រងកម្ពុជា ដូចជាការរៀបចំបង្កើតក្រុមការងារចំរុះជាដើម
- ពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយរៀបចំនីតិវិធីប្រតិបត្តិ (SOP) របស់និយ័តករធានារ៉ាប់រងកម្ពុជា សម្រាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ

បន្ថែមលើកិច្ចសហប្រតិបត្តិការក្នុងប្រទេស និងផ្អែកលើនិន្នាការមួយចំនួននៃសេរីភាវូបនីយកម្ម និងសមាហរណកម្មតំបន់និងពិភពលោក ដែលបាននិងកំពុងផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស និយ័តករត្រូវពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យបានរឹងមាំនិងជាប្រចាំ ដោយចូលរួមវេទិកា កិច្ចប្រជុំ និងកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី សំដៅជំរុញការអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជាឱ្យមានសន្ទុះកាន់តែខ្លាំងឡើង។ ក្នុងរយៈពេល ៥ឆ្នាំនេះ **ន.ធ.ក.** ត្រូវ ÷

- ចូលរួមនិងតាមដានការអនុវត្តសេរីភាវូបនីយកម្ម និងសមាហរណកម្មក្នុងក្របខណ្ឌតំបន់តាមរយៈកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators

Meeting) និងកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ាន សម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) ជាដើម

- ចូលជាសមាជិកភាពឡើងវិញ ក្នុងក្របខណ្ឌសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervisors-IAIS)
- បន្តការចូលរួមក្នុងកិច្ចការតំបន់និងអន្តរជាតិ ដើម្បីចាប់យកកាលានុវត្តភាព ចំណេះដឹង និងបទពិសោធន៍ថ្មីៗ សម្រាប់អភិវឌ្ឍស្ថាប័ន និងវិស័យធានារ៉ាប់រង។

## ផ្នែកទី ៥ ÷ យន្តការអនុវត្តន៍ ការត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីធានាបាននូវគុណភាពនៃផែនការអភិវឌ្ឍន៍ស្ថាប័ននិយ័តករធានារ៉ាប់រងកម្ពុជា ក្នុងគោលដៅសម្រេចឱ្យបាននូវសូចនាកររួមពីរសម្រាប់វាស់ការរីកចម្រើននៃវិស័យធនាធានារ៉ាប់រងកម្ពុជា សម្រាប់រយៈពេល ៥ឆ្នាំ គឺ អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច (Insurance Penetration) **២%** និងដង់ស៊ីតេធានារ៉ាប់រង (Insurance Density) **៤០ដុល្លារក្នុងមនុស្សម្នាក់** នៅឆ្នាំ២០២៥ យន្តការអនុវត្តន៍ ការត្រួតពិនិត្យ និងការវាយតម្លៃផែនការអភិវឌ្ឍន៍ស្ថាប័ននេះ ត្រូវកំណត់ដូចខាងក្រោម÷

### ៥.១. យន្តការអនុវត្តន៍

ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ ក្នុងការអនុវត្តនូវផែនការសកម្មភាពខាងលើនេះ ទាមទារឱ្យមានផងដែរនូវកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ និងការបែងចែកការទទួលខុសត្រូវច្បាស់លាស់ ដូចខាងក្រោម÷

- **ការអនុវត្ត**÷ **ន.ធ.ក.** មានតួនាទីជាអ្នកអនុវត្តនូវផែនការអភិវឌ្ឍន៍ស្ថាប័ននេះ
- **ការត្រួតពិនិត្យ**÷ **ន.ធ.ក.** មានតួនាទីជាអ្នកត្រួតពិនិត្យ ដោយមានកិច្ចសហការនិងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋានរបស់ **អ.ស.ហ.** ជាពិសេសអង្គភាពសវនកម្មផ្ទៃក្នុង
- **ការវាយតម្លៃ**÷ ក្រុមប្រឹក្សា **អ.ស.ហ.** ជាអ្នកដឹកនាំការងារវាយតម្លៃ និងកែសម្រួលផែនការ និងសកម្មភាពការងាររបស់ស្ថាប័ន **ន.ធ.ក.**។

### ៥.២. ការត្រួតពិនិត្យ និងការវាយតម្លៃ

នៅក្នុងដំណើរការអនុវត្តការត្រួតពិនិត្យនិងការវាយតម្លៃផែនការអភិវឌ្ឍន៍ស្ថាប័ន **ន.ធ.ក.** ត្រូវរៀបចំឱ្យមាន÷

- ការត្រួតពិនិត្យនិងការវាយតម្លៃផែនការអភិវឌ្ឍ នាពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិនៃការអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ន

- ភាពបន្ស៊ីគ្នារវាងផែនការថវិការបស់ **ន.ធ.ក.** ជាមួយនឹងសូចនាករនៃសកម្មភាពការងារ ដើម្បីធានាបាននូវវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារ និងប្រសិទ្ធភាពនៃការត្រួតពិនិត្យនិងការវាយតម្លៃ
- ភាពជាក់លាក់នៃការកំណត់សូចនាកររបស់សកម្មភាពការងារ និងភាពបត់បែន ចំពោះការអនុវត្តយន្តការត្រួតពិនិត្យនិងវាយតម្លៃផែនការអភិវឌ្ឍន៍និងសកម្មភាពការងារ ក្នុងការកែសម្រួលសូចនាករទាំងឡាយណាដែលមានលក្ខណៈស្មុគស្មាញ ដើម្បីចៀសវាងសូចនាករគោលដៅអរូបី ដែលមានការលំបាកក្នុងការសម្រេចបាន និងអាចទទួលយកបាននូវសូចនាករថ្មីៗជំនួសវិញ
- ការចូលរួមអនុវត្តផែនការអភិវឌ្ឍន៍ស្ថាប័ននេះ ពីគ្រប់នាយកដ្ឋាននិងការិយាល័យក្រោមឱវាទរបស់ **ន.ធ.ក.** តាមតួនាទីនិងភារកិច្ចរៀងៗខ្លួន
- ការរៀបចំរបាយការណ៍លទ្ធផល នៃការអនុវត្តសកម្មភាពការងារប្រចាំឆ្នាំ ជូនក្រុមប្រឹក្សា **អ.ស.ហ.** ក្នុងការពិនិត្យ ណែនាំ និងអនុម័តជាយថាហេតុលើការស្នើសុំកែសម្រួល និងការធ្វើបច្ចុប្បន្នភាពនានា។

## ផ្នែកទី ៦ ÷ សន្និដ្ឋាន

ជាមួយនឹងមហិច្ឆតាប្រាកដនិយមក្នុងការធានាបាននូវភាពធន់ និងឧត្តមភាពប្រកួតប្រជែង ប្រកបដោយចីរភាពរបស់គ្រឹះស្ថានធានារ៉ាប់រងទាំងអស់ **ន.ធ.ក.** ក្នុងការបំពេញមុខងារជាសេនាធិការរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ មានទិសដៅច្បាស់លាស់ក្នុងការប្រែក្លាយជាស្ថាប័នមួយដែលមានសមត្ថភាព ប្រកបដោយវិជ្ជាជីវៈ និងទទួលបានជំនឿទុកចិត្តខ្ពស់ពីសំណាក់មហាជន។ ដើម្បីសម្រេចបាននូវមហិច្ឆតាខាងលើ ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា (២០២១-២០២៥) មានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់បង្គោលចរនាំផ្លូវនិងតម្រង់ទិស សម្រាប់ **ន.ធ.ក.** អនុវត្តនូវសកម្មភាពការងារអាទិភាពដែលបានដាក់ចេញឱ្យបានរលូន ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព។ ផែនការនេះផ្តល់នូវក្របខណ្ឌយុទ្ធសាស្ត្រមួយប្រកបដោយការពិចារណាល្អិតល្អន់ ដោយដាក់ចេញនូវសសរស្តម្ភសំខាន់ៗទាំងបី ដែលប្រការនេះបានអនុញ្ញាតឱ្យ **ន.ធ.ក.** ពង្រឹងនិងពង្រីកនូវសមត្ថភាពស្ថាប័ន ការតភ្ជាប់ និងកិច្ចសហប្រតិបត្តិការបានល្អប្រសើរ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព តាមរយៈសកម្មភាពការងារលម្អិតនីមួយៗដែលមានភាពជាក់លាក់ មានភាពជាប់ទាក់ទងគ្នា អាចវាស់វែងបាន អាចសម្រេចបាន និងមានពេលវេលាកំណត់ច្បាស់លាស់។ ជាមួយគ្នានេះ ផ្អែកលើសក្តានុពលនិងភាពរឹងមាំនៃទីផ្សារធានារ៉ាប់រងនៅកម្ពុជា បន្ថែមដោយការតម្រង់ទិសដៅច្បាស់លាស់

តាមរយៈគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា (២០២១-២០៣០) និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា (២០២១-២០២៥) សូចនាករសំខាន់ៗចំនួនពីរ សម្រាប់វាស់វែងការរីកចម្រើននៃវិស័យធានារ៉ាប់រង គឺអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច (Insurance Penetration) ២% និងដង់ស៊ីតេធានារ៉ាប់រង (Insurance Density) ៤០ដុល្លារ ក្នុងមនុស្សម្នាក់ នៅឆ្នាំ២០២៥។

# ផ្នែកទី ៧÷ តារាងសកម្មភាពការងារនៃផែនការអភិវឌ្ឍន៍ស្ថាប័ន

| តារាងម៉ាទ្រីស÷ សកម្មភាពការងារនៃផែនការអភិវឌ្ឍន៍ស្ថាប័ន | | | |
|---|---|---|---|
| **ល.រ** | **សកម្មភាព** | **សកម្មភាពលម្អិត** | **សូចនាករ** |
| **ឆ្នាំ២០២១** | | | |
| **១.សមត្ថភាពស្ថាប័ន** (Capacity) | | | |
| *១.១.* | *រចនាសម្ព័ន្ធស្ថាប័ន* | – រៀបចំបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធស្ថាប័ននិយ័តករធានារ៉ាប់រងកម្ពុជា<br>– រៀបចំបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធរបស់អង្គភាពក្រោមឱវាទ **ន.ធ.ក.** | – អនុក្រឹត្យ លេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានអនុម័ត<br>– ប្រកាស លេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០ ២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទរបស់និយ័តករធានារ៉ាប់រងកម្ពុជាត្រូវបានអនុម័ត។ |
| *១.២.* | *អភិបាលកិច្ច* | – រៀបចំបទប្បញ្ញត្តិតែងតាំងថ្នាក់ដឹកនាំអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ<br>– រៀបចំបទប្បញ្ញត្តិតែងតាំងអគ្គនាយកនៃ **ន.ធ.ក**<br>– រៀបចំបទប្បញ្ញត្តិតែងតាំងថ្នាក់ដឹកនាំនៃ **ន.ធ.ក.**<br>– រៀបចំបទប្បញ្ញត្តិតែងតាំងថ្នាក់ដឹកនាំការិយាល័យនៃ **ន.ធ.ក.**<br>– រៀបចំចាត់តាំងមន្ត្រីឱ្យបំពេញការងារតាមនាយកដ្ឋាននៃ | – អនុក្រឹត្យ លេខ ២១០ អនក្រ. តត ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារត្រូវបានអនុម័ត<br>– ព្រះរាជក្រឹត្យលេខ នស/រកត/០២២១/១៤៤ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការតែងតាំងមុខតំណែងនិងផ្តល់ឋានៈដល់មន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបាន |

| | | | |
|---|---|---|---|
| | | **ន.ធ.ក.**<br>– រៀបចំបទប្បញ្ញត្តិបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់មន្ត្រីនិងថ្នាក់ដឹកនាំ **ន.ធ.ក.** | អនុម័ត<br>– អនុក្រឹត្យ លេខ២៨៨ អនក្រ.តត ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ២០២១ និងអនុក្រឹត្យលេខ៣៦២ អនក្រ.តត ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការតែងតាំងមន្ត្រីរាជការនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (ការតែងតាំងអគ្គនាយករង និងប្រធាននាយកដ្ឋាន) ត្រូវបានអនុម័ត<br>– ប្រកាស លេខ០១២ អ.ស.ហ.ប្រក ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ ២០២១ ស្តីពីការតែងតាំងមន្ត្រីរាជការនៃនិយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបានអនុម័ត<br>– លិខិតបង្គាប់ការលេខ ០០២ ន.ធ.ក./សរ ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ ចាត់តាំងមន្ត្រីឱ្យបំពេញការងារតាមនាយកដ្ឋាន នៃ **ន.ធ.ក.** ត្រូវបានដាក់ឱ្យអនុវត្ត<br>– សេចក្តីសម្រេចលេខ០០១ អ.ស.ហ.ន.ធ.ក. ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើតគណៈកម្មការវាយតម្លៃសមិទ្ធកម្មរបស់និយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្ត។ |
| *១.៣.* | ***ធនធានមនុស្ស*** | – ជ្រើសរើសមន្ត្រី ២១រូប<br>– រៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– រៀបចំបទប្បញ្ញត្តិកំណត់លក្ខន្តិកៈមន្ត្រីនៃ **អ.ស.ហ.** | – មន្ត្រីថ្មីចំនួន ២១រូប ត្រូវបានជ្រើសរើសនិងចូលបម្រើការងារ<br>– របាយការណ៍អំពីវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាន សម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– ប្រកាសលេខ ០១០ អ.ស.ហ.ប្រក ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ |

| | | | |
|---|---|---|---|
| | | – រៀបចំបទប្បញ្ញត្តិកំណត់ប្រាក់បៀវត្សសម្រាប់មន្ត្រីលក្ខន្តិកៈ | ស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់ **ន.ធ.ក.** ត្រូវបានអនុម័ត<br>– ប្រកាសលេខ០២២ អ.ស.ហ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការកំណត់ប្រាក់បៀវត្សសម្រាប់មន្ត្រីលក្ខន្តិកៈ និងមន្ត្រីជាប់កិច្ចសន្យារបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្ត |
| ***១.៤.*** | ***បរិស្ថាននិងលក្ខខណ្ឌការងារ*** | – សិក្សារៀបចំពង្រីកការិយាល័យធ្វើការនៅអគាររដ្ឋបាលថ្មីបន្ថែម (មានផែនការសាងសង់រួចហើយ)<br>– រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងរដ្ឋបាល (Administration Information System -AIS) ដំណាក់កាលទី១ សម្រាប់គ្រប់គ្រងចលនាឯកសាររដ្ឋបាលផ្ទៃក្នុងរបស់និយ័តករ<br>– រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីនិងថ្នាក់ដឹកនាំ ដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម | – របាយការណ៍វឌ្ឍនភាពនៃការសិក្សារៀបចំពង្រីកការិយាល័យធ្វើការនៅអគាររដ្ឋបាលថ្មីបន្ថែមចំនួន ១ច្បាប់<br>– ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងរដ្ឋបាល (Administration Information System-AIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យប្រើប្រាស់<br>– របាយការណ៍អំពី ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិងសម្ភារៈការិយាល័យដែលបានបំពាក់សម្រាប់បំពេញការងារដល់មន្ត្រីនិងថ្នាក់ដឹកនាំដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម |
| | | **២.ការតភ្ជាប់** (Connectivity) | |
| ***២.១.*** | ***ការតភ្ជាប់ផ្ទៃក្នុង*** | – រៀបចំកម្មវិធីបណ្តុះបណ្តាលមូលដ្ឋាននិងឯកទេសអំពីវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអនុវត្តជាផ្លូវការ | – កម្មវិធីបណ្តុះបណ្តាលមូលដ្ឋាន និងឯកទេសអំពីវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងសម្រាប់ក្រុមហ៊ុនធានារ៉ាប់រងអនុវត្តជាផ្លូវការ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត |
| ***២.២.*** | ***ការតភ្ជាប់*** | – រៀបចំប្រព័ន្ធបច្ចេកវិទ្យាទទួលនិងគ្រប់គ្រងបណ្តឹងធានា | – ប្រព័ន្ធបច្ចេកវិទ្យាទទួលនិងគ្រប់គ្រងបណ្តឹងធានារ៉ាប់រងតាម |

| | | | |
|---|---|---|---|
| | *ផ្នែកទន់* | រ៉ាប់រងតាមអនឡាញ (Insurance Complaint Management Information System-ICMIS)<br>– រៀបចំគេហទំព័ររបស់ **ន.ធ.ក.**<br>– រៀបចំប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យទីផ្សារ (Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី១ | អនឡាញ (Insurance Complaint Management Information System-ICMIS) ត្រូវបានដាក់ឱ្យប្រើប្រាស់<br>– គេហទំព័ររបស់ **ន.ធ.ក.** ត្រូវបានដាក់ឱ្យប្រើប្រាស់<br>– រៀបចំប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យទីផ្សារ (Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យប្រើប្រាស់ |
| **៣. កិច្ចសហប្រតិបត្តិការ (Cooperation)** | | | |
| *៣.១.* | *កិច្ចសហប្រតិបត្តិការក្នុងប្រទេស* | – ពង្រឹងយន្តការសម្របសម្រួល និងចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ<br>– ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទ **អ.ស.ហ.** | – ប្រកាសស្តីពី ការបង្កើតក្រុមការងារប្រតិបត្តិកិច្ចការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមចំណុះ ចំនួន ១ច្បាប់<br>– របាយការណ៍វឌ្ឍនភាពនៃយន្តការសម្របសម្រួល និងចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ<br>– របាយការណ៍លទ្ធផល នៃការចូលរួមកិច្ចប្រជុំអន្តរនិយ័តករក្រោម **អ.ស.ហ.** |
| *៣.២.* | *កិច្ចសហប្រតិបត្តិការ* | – ចូលរួមនិងតាមដានកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន | – របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន |

| | | | |
|---|---|---|---|
| | ***អន្តរជាតិ*** | (ASEAN Insurance Regulators Meeting-AIRM)<br>– ចូលរួមនិងតាមដានកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក | (ASEAN Insurance Regulators Meeting-AIRM)<br>– របាយការណ៍វឌ្ឍនភាព នៃកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក |
| **ឆ្នាំ២០២២** | | | |
| **១. សមត្ថភាពស្ថាប័ន** (Capacity) | | | |
| ***១.១.*** | ***រចនាសម្ព័ន្ធស្ថាប័ន*** | – សិក្សាវិភាគមុខងារស្ថាប័ន **ន.ធ.ក.** ផ្អែកលើភាពចាំបាច់ | – របាយការណ៍លទ្ធផល នៃការវិភាគមុខងារស្ថាប័ន **ន.ធ.ក.** |
| ***១.២.*** | ***អភិបាលកិច្ច*** | – រៀបចំបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ **ន.ធ.ក.**<br>– រៀបចំបទប្បញ្ញត្តិទទួលស្គាល់មន្ត្រីលក្ខន្តិកៈ<br>– រៀបចំបទបញ្ជាផ្ទៃក្នុងរបស់និយ័តករធានារ៉ាប់រងកម្ពុជា<br>– រៀបចំវិធានស្តីពីយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពការងារ<br>– រៀបចំវិធានស្តីពី ស្តង់ដារ និងនីតិវិធីប្រតិបត្តិការរបស់ **ន.ធ.ក.**<br>– សិក្សានិងរៀបចំសំណើតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃ **ន.ធ.ក.** តាមភាពចាំបាច់នៃតួនាទីនិងភារកិច្ច | – សេចក្តីសម្រេចលេខ០០១ ន.ធ.ក./សរ ចុះថ្ងៃទី៣ ខែមករា ឆ្នាំ ២០២២ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំ នៃនិយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្ត<br>– ប្រកាសលេខ ០០៤ អ.ស.ហ.ប្រក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០២២ ស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ឱ្យចូលបម្រើការងារនៅនិយ័តករធានារ៉ាប់រងកម្ពុជា ចំនួន១ច្បាប់<br>– បទបញ្ជាផ្ទៃក្នុងរបស់និយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>– វិធានស្តីពីយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពការងារ ត្រូវបានដាក់ឱ្យអនុវត្ត<br>– វិធានស្តីពីស្តង់ដារ និងនីតិវិធីប្រតិបត្តិការរបស់ **ន.ធ.ក.** ត្រូវ |

| | | | |
|---|---|---|---|
| | | | បានដាក់ឱ្យអនុវត្ត<br>– ប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃ **ន.ធ.ក.** ត្រូវបានអនុម័ត |
| ***១.៣*** | ***ធនធានមនុស្ស*** | – ជ្រើសរើសមន្ត្រី ១០រូប<br>– រៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស<br>– រៀបចំប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រី **ន.ធ.ក** សម្រាប់ដំឡើងឋានៈនិងឋានន្តរស័ក្តិ និងផ្តល់ប្រាក់ឧបត្ថម្ភ ប្រាក់រង្វាន់ លិខិតឬបណ្ណសរសើរ មេដាយ ការងារនិងអត្ថប្រយោជន៍ផ្សេងៗ | – មន្ត្រីថ្មីចំនួន ១០រូប ដែលត្រូវបានជ្រើសរើសចូលបម្រើការងារ<br>– របាយការណ៍អំពីលទ្ធផល នៃវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– របាយការណ៍អំពីលទ្ធផល នៃការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស<br>– គោលការណ៍ណែនាំអំពី ប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រី **ន.ធ.ក** សម្រាប់ដំឡើងឋានៈនិងឋានន្តរស័ក្តិ និងផ្តល់ប្រាក់ឧបត្ថម្ភ ប្រាក់រង្វាន់ លិខិតឬបណ្ណសរសើរ មេដាយការងារនិងអត្ថប្រយោជន៍ផ្សេងៗ ត្រូវបានដាក់ឱ្យប្រើប្រាស់ |
| ***១.៤*** | ***បរិស្ថាននិងលក្ខខណ្ឌការងារ*** | – រៀបចំសាងសង់ការិយាល័យធ្វើការនៅអគាររដ្ឋបាលថ្មី<br>– រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងរដ្ឋបាល (Administration Information System-AIS) ដំណាក់កាលទី២<br>– រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យក្រុមហ៊ុន (Company Profile Management Information System-CPMIS) ដំណាក់កាលទី១ | – របាយការណ៍វឌ្ឍនភាពនៃការរៀបចំសាងសង់ការិយាល័យធ្វើការនៅអគាររដ្ឋបាលថ្មី<br>– ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងរដ្ឋបាល (Administration Information System-AIS) ដំណាក់កាលទី២ ត្រូវបានដាក់ឱ្យប្រើប្រាស់<br>– របាយការណ៍វឌ្ឍនភាព នៃការរៀបចំប្រព័ន្ធបច្ចេកវិទ្យា |

| | | | |
|---|---|---|---|
| | | – រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងវត្តមានរបស់មន្ត្រី (Attendance Management Information System-AMIS)<br>– រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មីដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម | គ្រប់គ្រងទិន្នន័យក្រុមហ៊ុន (Company Profile Management Information System-CPMIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យប្រើប្រាស់<br>– ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងវត្តមានមន្ត្រី (Attendance Management Information System-AMIS) ត្រូវបានដាក់ឱ្យដំណើការ<br>– របាយការណ៍អំពីឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិងសម្ភារៈការិយល័យដែលបានបំពាក់សម្រាប់បំពេញការងារដល់មន្ត្រីថ្មីដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម |
| **២. ការតភ្ជាប់** (Connectivity) | | | |
| *២.១.* | *ការតភ្ជាប់ផ្នែករឹង* | – រៀបចំពង្រឹងកម្មវិធីសិក្សា ជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា<br>– រៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា។ | – កម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ត្រូវបានដាក់ឱ្យអនុវត្ត ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា<br>– វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ត្រូវបានផ្តល់ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា |
| *២.២.* | *ការតភ្ជាប់ផ្នែកទន់* | – រៀបចំប្រព័ន្ធបច្ចេកវិទ្យាចុះបញ្ជីភ្នាក់ងារធានារ៉ាប់រង (Insurance Agent Registration Information System-IARIS) ដំណាក់កាលទី១ | – ប្រព័ន្ធបច្ចេកវិទ្យាចុះបញ្ជីភ្នាក់ងារធានារ៉ាប់រង (Insurance Agent Registration Information System-IARIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យដំណើការ |

| | | | |
|---|---|---|---|
| | | – រៀបចំប្រព័ន្ធប្រមូលនិងគ្រប់គ្រង ទិន្នន័យទីផ្សារធានារ៉ាប់រង (Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី២<br>– រៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | – ប្រព័ន្ធប្រមូលនិងគ្រប់គ្រង ទិន្នន័យទីផ្សារធានារ៉ាប់រង (Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី២ ត្រូវបានដាក់ឱ្យដំណើការ<br>– របាយការណ៍វឌ្ឍនភាពនៃការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) |
| **៣. កិច្ចសហប្រតិបត្តិការ** (Cooperation) | | | |
| *៣.១.* | *កិច្ចសហប្រតិបត្តិការក្នុងប្រទេស* | – រៀបចំបង្កើតភាពជាដៃគូច្បាស់លាស់ រវាង **ន.ធ.ក.** និងប្រតិបត្តិករធានារ៉ាប់រង<br>– ជំរុញនិងសម្របសម្រួលវិស័យឯកជនធានារ៉ាប់រងឱ្យបានចូលរួមក្នុងវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន<br>– ធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារអន្តរក្រសួង ដើម្បីរៀបចំប្រជុំឱ្យបានទៀងទាត់និងជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច<br>– ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.**<br>– ពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញប្រតិបត្តិការផ្តល់សេវាធានារ៉ាប់រងតាមរយៈស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលហៅថា Bancassurance | – កម្មវិធីសម្រាប់វេទិកាភាពជាដៃគូរវាង **ន.ធ.ក.** និងប្រតិបត្តិករធានារ៉ាប់រង ត្រូវបានកំណត់ច្បាស់លាស់សម្រាប់អនុវត្តប្រចាំឆ្នាំ<br>– តំណាងសមាគមធានារ៉ាប់រងកម្ពុជា ត្រូវបានអនុញ្ញាតចូលរួមក្នុងវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន<br>– ប្រកាសស្តីពីសមាសភាពក្រុមការងារអន្តរក្រសួងអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ត្រូវបានអនុម័ត<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំក្រុមការងារអន្តរក្រសួងអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការរវាង **ន.ធ.ក.** និងនិយ័តករក្រោមឱវាទរបស់ **អ.ស.ហ.**<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការស្តីពី Bancassurance |

| | | | |
|---|---|---|---|
| | | – រៀបចំនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ របស់ន.ធ.ក. ត្រូវបានសិក្សា និងរៀបចំកម្រិត **ន.ធ.ក.**<br>– រៀបចំក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងសមត្ថកិច្ចរួមរបស់ក្រសួងពាណិជ្ជកម្ម និងនិយ័តករធានារ៉ាប់រងកម្ពុជា | – របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹង ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ<br>– នីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ របស់**ន.ធ.ក.** ត្រូវបានសិក្សានិងរៀបចំកម្រិត **ន.ធ.ក.**<br>– ប្រកាសស្តីពីការបង្កើតក្រុមការងារចំរុះរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងពាណិជ្ជកម្ម ត្រូវបានអនុម័ត |
| *៣.២.* | ***កិច្ចសហប្រតិបត្តិការអន្តរជាតិ*** | – ចូលជាសមាជិកភាពឡើងវិញ ក្នុងសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– ចូលរួមនិងតាមដានកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– ចូលរួមនិងតាមដានកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) | – របាយការណ៍វឌ្ឍនភាព នៃការសិក្សាការចូលជាសមាជិកភាពឡើងវិញ ក្នុងសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– របាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services |

| | | | |
|---|---|---|---|
| | | និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក | Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក |
| **ឆ្នាំ២០២៣** | | | |
| **១. សមត្ថភាពស្ថាប័ន** (Capacity) | | | |
| ***១.១.*** | ***រចនាសម្ព័ន្ធស្ថាប័ន*** | – សិក្សាវិភាគមុខងារស្ថាប័ន **ន.ធ.ក.** ផ្អែកលើភាពចាំបាច់<br>– រៀបចំវិសោធនកម្មបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធស្ថាប័នប្រសិនមានភាពចាំបាច់។ | – របាយការណ៍វិភាគមុខងារស្ថាប័ន **ន.ធ.ក.**<br>– បទប្បញ្ញត្តិកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន **ន.ធ.ក.** ត្រូវបានអនុម័ត |
| ***១.២.*** | ***អភិបាលកិច្ច*** | – រៀបចំបទប្បញ្ញត្តិទទួលស្គាល់មន្ត្រីលក្ខន្តិកៈបន្ថែម<br>– រៀបចំសំណើតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា តាមភាពចាំបាច់។ | – ប្រកាសស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** បន្ថែមឱ្យចូលបម្រើការងារនៅនិយ័តករធានារ៉ាប់រងកម្ពុជា ត្រូវបានអនុម័ត<br>– ប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃ **ន.ធ.ក.** ត្រូវបានអនុម័ត |
| ***១.៣.*** | ***ធនធានមនុស្ស*** | – ជ្រើសរើសមន្ត្រី ១៤រូប<br>– រៀបចំវគ្គបណ្តុះបណ្តាលជំនាញសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស។ | – មន្ត្រីថ្មីចំនួន ១៤ រូប ដែលត្រូវបានជ្រើសរើសចូលបម្រើការងារ<br>– របាយការណ៍អំពីលទ្ធផល នៃការរៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាន សម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– របាយការណ៍អំពីលទ្ធផល នៃការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស |
| ***១.៤.*** | ***បរិស្ថាននិងលក្ខខណ្ឌ*** | – បន្តសាងសង់ការិយាល័យធ្វើការនៅអគាររដ្ឋបាលថ្មី | – របាយការណ៍វឌ្ឍនភាពនៃការសាងសង់ការិយាល័យធ្វើការនៅ |

| | | | |
|---|---|---|---|
| | *ការងារ* | – រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមហ៊ុន (Company Profile Management Information System-CPMIS) ដំណាក់កាលទី២<br>– រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មី ដូចជា កុំព្យូទ័រ បណ្ដាញតភ្ជាប់ បណ្ដាញអ៊ិនធឺណិត តុ និងទូ ជាដើម | អគាររដ្ឋបាលថ្មី<br>– ប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមហ៊ុន (Company Profile Management Information System-CPMIS) ដំណាក់កាលទី២ ត្រូវបានដាក់ឱ្យដំណើរការ<br>– របាយការណ៍អំពីឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិងសម្ភារៈការិយាល័យដែលបានបំពាក់សម្រាប់បំពេញការងារដល់មន្ត្រីថ្មី ដូចជា កុំព្យូទ័រ បណ្ដាញតភ្ជាប់ បណ្ដាញអ៊ិនធឺណិត តុ និងទូ ជាដើម |
| **២. ការតភ្ជាប់ (Connectivity)** | | | |
| *២.១.* | *ការតភ្ជាប់ផ្នែករឹង* | – បន្តពង្រឹងកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថាន ឧត្តមសិក្សា<br>– ពង្រឹងគុណភាពនៃការបណ្ដុះបណ្ដាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា<br>– សិក្សាសមិទ្ធិលទ្ធភាពអំពីការបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង | – របាយការណ៍វឌ្ឍនភាព នៃការរៀបចំពង្រឹងកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា<br>– របាយការណ៍វឌ្ឍនភាពនៃការរៀបចំការបណ្ដុះបណ្ដាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា<br>– របាយការណ៍វឌ្ឍនភាពនៃការសិក្សាសមិទ្ធិលទ្ធភាពអំពីការបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង |
| *២.២.* | *ការតភ្ជាប់ផ្នែកទន់* | – រៀបចំប្រព័ន្ធបច្ចេកវិទ្យា ចុះបញ្ជីអន្តរការីធានារ៉ាប់រង (Insurance Agent Registration Information System-IARS) ដំណាក់កាលទី២ | – របាយការណ៍វឌ្ឍនភាពនៃការរៀបចំប្រព័ន្ធបច្ចេកវិទ្យា ចុះបញ្ជីអន្តរការីធានារ៉ាប់រង (Insurance Agent Registration System-IARS) ដំណាក់កាលទី២ ត្រូវបានដាក់ឱ្យដំណើរការ |

| | | | |
|---|---|---|---|
| | | – រៀបចំប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យទីផ្សារធានារ៉ាប់រង ( Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី៣<br>– សិក្សាប្រមូលធាតុចូលដើម្បីរៀបចំប្រព័ន្ធបច្ចេកវិទ្យាសម្រាប់វិភាគនិងផ្តល់សញ្ញាមុន (Early Warning System)<br>– រៀបចំក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech)<br>– សិក្សាសមិទ្ធិលទ្ធផល ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងវិស័យធានារ៉ាប់រងកម្ពុជា និងក្នុងក្របខណ្ឌសមាហរណកម្មតំបន់ | – របាយការណ៍វឌ្ឍនភាពនៃការរៀបចំប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យទីផ្សារធានារ៉ាប់រង ( Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី៣ ត្រូវបានដាក់ឱ្យដំណើការ<br>– របាយការណ៍អំពីលទ្ធផលនៃការសិក្សារៀបចំប្រព័ន្ធបច្ចេកវិទ្យាសម្រាប់វិភាគនិងផ្តល់សញ្ញាមុន (Early Warning System)<br>– ការអនុម័តដាក់ឱ្យប្រើប្រាស់ក្របខណ្ឌយុទ្ធសាស្រ្តអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech)<br>– របាយការណ៍អំពីសមិទ្ធិលទ្ធផល ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងវិស័យធានារ៉ាប់រងកម្ពុជា និងក្នុងក្របខណ្ឌសមាហរណកម្មតំបន់ |
| **៣. កិច្ចសហប្រតិបត្តិការ** (Cooperation) | | | |
| ***៣.១.*** | ***កិច្ចសហប្រតិបត្តិការក្នុងប្រទេស*** | – ពង្រឹងភាពជាដៃគូរវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងប្រតិបត្តិករធានារ៉ាប់រង<br>– បន្តពង្រឹងតួនាទីនិងភារកិច្ចរបស់ក្រុមការងារអន្តរក្រសួងដើម្បីជំរុញការអនុវត្ត ការធានារ៉ាប់រងជាកាតព្វកិច្ច<br>– បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយ និយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.**<br>– បន្តពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិកម្ពុជា | – របាយការណ៍អំពីលទ្ធផលនៃវេទិកាភាពជាដៃគូរវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងប្រតិបត្តិករធានារ៉ាប់រង<br>– របាយការណ៍អំពីលទ្ធផលការងាររបស់ក្រុមការងារអន្តរក្រសួងក្នុងការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច<br>– របាយការណ៍អំពីលទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាង**ន.ធ.ក.** និងនិយ័តករក្រោមឱវាទរបស់ **អ.ស.ហ.**<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការស្តីពី |

| | | | |
|---|---|---|---|
| | | ដើម្បីជំរុញការផ្តល់សេវាធានារ៉ាប់រងតាមរយៈស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលហៅថា Bancassurance<br>– បន្តពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹង ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និង ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | Bancassurance<br>– របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹង ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ |
| ***៣.២.*** | ***កិច្ចសហប្រតិបត្តិការអន្តរជាតិ*** | – ចូលរួមនិងតាមដាន កិច្ចប្រជុំសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– ចូលរួមនិងតាមដានកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– ចូលរួមនិងតាមដាន កិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក | – របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និង កិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក |
| **ឆ្នាំ២០២៤** | | | |
| **១.សមត្ថភាពស្ថាប័ន** (Capacity) | | | |
| ***១.១.*** | ***រចនាសម្ព័ន្ធស្ថាប័ន*** | – បន្តសិក្សាវិភាគមុខងារស្ថាប័ន **ន.ធ.ក** ផ្អែកលើភាពចាំបាច់<br>– រៀបចំវិសោធនកម្មបទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធស្ថាប័ន | – របាយការណ៍វិភាគកមុខងារស្ថាប័ន **ន.ធ.ក**<br>– បទប្បញ្ញត្តិកំណត់រចនាសម្ព័ន្ធស្ថាប័ន **ន.ធ.ក** ត្រូវបានអនុម័ត |

| | | | |
|---|---|---|---|
| | | ប្រសិទ្ធភាពចាំបាច់ | |
| ១.២. | *អភិបាលកិច្ច* | – រៀបចំបទប្បញ្ញត្តិទទួលស្គាល់មន្ត្រីលក្ខន្តិកៈបន្ថែម<br>– រៀបចំសំណើតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងមន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា តាមភាពចាំបាច់ | – ប្រកាសស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ឱ្យចូលបម្រើការងារនៅ **ន.ធ.ក.** ត្រូវបានអនុម័ត<br>– ប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន និងការិយាល័យនៃ **ន.ធ.ក** ត្រូវបានអនុម័ត |
| ១.៣. | *ធនធានមនុស្ស* | – ជ្រើសរើសមន្ត្រី ៥០រូប<br>– រៀបចំវគ្គបណ្តុះបណ្តាលជំនាញសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស | – មន្ត្រីថ្មីចំនួន ៥០រូប ត្រូវបានជ្រើសរើសចូលបម្រើការងារ<br>– របាយការណ៍អំពីការរៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– របាយការណ៍អំពីការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស |
| ១.៤. | *បរិស្ថាននិងលក្ខខណ្ឌការងារ* | – បញ្ចប់ការសាងសង់អគាររដ្ឋបាលបន្ថែមរបស់ ន.ធ.ក.<br>– រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិងសម្ភារៈការិយាល័យ សម្រាប់បំពេញការងាររបស់មន្ត្រីថ្មី ដូចជាកុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត ទូ និងទូ ជាដើម | – អគាររដ្ឋបាលថ្មីត្រូវបានដាក់ឱ្យប្រើប្រាស់<br>– របាយការណ៍អំពីឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យដែលបានបំពាក់សម្រាប់បំពេញការងាររបស់មន្ត្រីថ្មី ដូចជាកុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ ទូ ជាដើម |
| **២.ការតភ្ជាប់ (Connectivity)** | | | |
| ២.១. | *ការតភ្ជាប់ផ្ទៃក្នុង* | – បន្តពង្រឹងកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា | – របាយការណ៍វឌ្ឍនភាពនៃការរៀបចំពង្រឹងកម្មវិធីសិក្សា ជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា |

| | | | |
|---|---|---|---|
| | | – បន្តពង្រឹងគុណភាពនៃការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការ ជាមួយសមាគមធានារ៉ាប់រងកម្ពុជា<br>– រៀបចំបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង | – របាយការណ៍វឌ្ឍនភាពនៃការរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា<br>– គម្រោងបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រងត្រូវបានអនុម័ត |
| *២.២.* | *ការតភ្ជាប់ផ្ទៃកទន់* | – សិក្សារៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យការធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច (MTPL Data Management System)<br>– រៀបចំប្រព័ន្ធបច្ចេកវិទ្យាសម្រាប់វិភាគនិងផ្តល់សញ្ញាមុន (Early Warning System) ដំណាក់កាលទី១<br>– បន្តសិក្សាសមិទ្ធិលទ្ធផលក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា និងក្នុងក្របខណ្ឌសមាហរណកម្មតំបន់ | – របាយការណ៍លទ្ធផលនៃការសិក្សារៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យការធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច (MTPL Data Management System) ត្រូវបានអនុម័ត<br>– ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់វិភាគនិងផ្តល់សញ្ញាមុន (Early Warning System) ដំណាក់កាលទី១ត្រូវបានដាក់ឱ្យដំណើរការ<br>– របាយការណ៍វឌ្ឍនភាពនៃការសិក្សាសមិទ្ធិលទ្ធផល ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រងក្នុងវិស័យធានារ៉ាប់រងកម្ពុជា និងក្នុងក្របខណ្ឌសមាហរណកម្មតំបន់ |
| **៣. កិច្ចសហប្រតិបត្តិការ** (Cooperation) | | | |
| *៣.១.* | *កិច្ចសហប្រតិបត្តិការក្នុងប្រទេស* | – បន្តពង្រឹងភាពជាដៃគូ រវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងប្រតិបត្តិករធានារ៉ាប់រង<br>– បន្តពង្រឹងតួនាទីនិងភារកិច្ចរបស់ក្រុមការងារអន្តរក្រសួង ដើម្បីជំរុញការអនុវត្ត ការធានារ៉ាប់រងជាកាតព្វកិច្ច<br>– បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.** | – របាយការណ៍វឌ្ឍនភាពនៃវេទិកាភាពជាដៃគូរវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងប្រតិបត្តិករធានារ៉ាប់រង<br>– របាយការណ៍លទ្ធផលការងាររបស់ក្រុមការងារអន្តរក្រសួងអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការជាមួយនិយ័តករក្រោមឱវាទរបស់ **អ.ស.ហ.** |

| | | | |
|---|---|---|---|
| | | – បន្តពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិកម្ពុជា ដើម្បីជំរុញប្រតិបត្តិការផ្តល់សេវាធានារ៉ាប់រងតាមរយៈស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលហៅថា Bancassurance<br>– បន្តពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | – របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការស្តីពី Bancassurance<br>– របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹង ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ |
| ***៣.២.*** | ***កិច្ចសហប្រតិបត្តិការអន្តរជាតិ*** | – ចូលរួមនិងតាមដាន កិច្ចប្រជុំសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– ចូលរួមនិងតាមដាន កិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– ចូលរួមនិងតាមដាន កិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក | – របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក |
| **ឆ្នាំ២០២៥** | | | |
| **១.សមត្ថភាពស្ថាប័ន** (Capacity) | | | |
| ***១.១.*** | ***រចនាសម្ព័ន្ធស្ថាប័ន*** | – បន្តសិក្សាវិភាគមុខងារស្ថាប័ន **ន.ធ.ក.** ផ្អែកលើភាពចាំបាច់<br>– រៀបចំវិសោធនកម្មបទប្បញ្ញត្តិកំណត់ រចនាសម្ព័ន្ធស្ថាប័ន | – របាយការណ៍វិភាគមុខងារស្ថាប័ន **ន.ធ.ក.**<br>– បទប្បញ្ញត្តិកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន **ន.ធ.ក.** ត្រូវបាន |

| | | ប្រសិនមានភាពចាំបាច់ | អនុម័ត |
|---|---|---|---|
| ***១.២.*** | ***អភិបាលកិច្ច*** | – រៀបចំបទប្បញ្ញត្តិទទួលស្គាល់មន្ត្រីលក្ខន្តិកៈបន្ថែម<br>– រៀបចំសំណើតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និង មន្ត្រីនៃនិយ័តករធានារ៉ាប់រងកម្ពុជា តាមភាពចាំបាច់ | – ប្រកាសស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ឱ្យចូលបម្រើការងារនៅនិយ័តករធានារ៉ាប់រងកម្ពុជា<br>– ប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាននិង ការិយាល័យនៃ **ន.ធ.ក.** ត្រូវបានអនុម័ត |
| ***១.៣.*** | ***ធនធានមនុស្ស*** | – ជ្រើសរើសមន្ត្រី ៥០រូប<br>– រៀបចំវគ្គបណ្តុះបណ្តាលជំនាញសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស | – មន្ត្រីថ្មីចំនួន ៥០ រូប ត្រូវបានជ្រើសរើសចូលបម្រើការងារ<br>– របាយការណ៍លទ្ធផលនៃការរៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋាន សម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស<br>– របាយការណ៍អំពីការចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលានិងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស |
| ***១.៤.*** | ***បរិស្ថាននិងលក្ខខណ្ឌការងារ*** | – រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាននិងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មី ដូចជាកុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម<br>– សិក្សាសមិទ្ធិលទ្ធផលលើការលើកកម្ពស់បរិស្ថាន និងលក្ខខណ្ឌការងារដល់មន្ត្រី **ន.ធ.ក.** | – របាយការណ៍អំពីឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មី ដូចជាកុំព្យូទ័របណ្តាញតភ្ជាប់ បណ្តាញអ៊ិនធឺណិត តុ និងទូ ជាដើម<br>– របាយការណ៍វឌ្ឍនភាពនៃការសិក្សាសមិទ្ធិលទ្ធផលលើការលើកកម្ពស់បរិស្ថាន និងលក្ខខណ្ឌការងារដល់មន្ត្រី **ន.ធ.ក.** |
| | | **២.ការតភ្ជាប់** (Connectivity) | |
| ***២.១.*** | ***ការតភ្ជាប់ផ្នែករឹង*** | – បន្តពង្រឹងកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សាដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និង | – របាយការណ៍វឌ្ឍនភាពនៃការរៀបចំពង្រឹងកម្មវិធីសិក្សា ជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួង |

| | | | |
|---|---|---|---|
| | | គ្រឹះស្ថានឧត្តមសិក្សា<br>– បន្តពង្រឹងគុណភាព នៃការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា<br>– បន្តរៀបចំបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង។ | អប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា<br>– របាយការណ៍វឌ្ឍនភាពនៃការរៀបចំការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា<br>– របាយការណ៍វឌ្ឍនភាពនៃការបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង |
| *២.២.* | *ការតភ្ជាប់ផ្នែកទន់* | – បន្តសិក្សាសមិទ្ធិលទ្ធផលក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា | – របាយការណ៍នៃការសិក្សាសមិទ្ធិលទ្ធផល ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងវិស័យធានារ៉ាប់រងកម្ពុជា |
| **៣.កិច្ចសហប្រតិបត្តិការ** (Cooperation) | | | |
| *៣.១.* | *កិច្ចសហប្រតិបត្តិការក្នុងប្រទេស* | – បន្តពង្រឹងភាពជាដៃគូ រវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងប្រតិបត្តិករធានារ៉ាប់រង<br>– បន្តពង្រឹងតួនាទីនិងភារកិច្ចរបស់ក្រុមការងារអន្តរក្រសួងដើម្បីជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច<br>– បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.**<br>– បន្តពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិកម្ពុជាដើម្បីជំរុញប្រតិបត្តិការផ្តល់សេវាធានារ៉ាប់រងតាមរយៈស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុ ដែលហៅថា Bancassurance<br>– បន្តពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និង | – របាយការណ៍វឌ្ឍនភាពនៃវេទិកាភាពជាដៃគូ រវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងប្រតិបត្តិករធានារ៉ាប់រង<br>– របាយការណ៍អំពីលទ្ធផលរបស់ក្រុមការងារអន្តរក្រសួងអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច<br>– របាយការណ៍លទ្ធផលនៃកិច្ចសហប្រតិបត្តិការរវាង **ន.ធ.ក.** និងនិយ័តករក្រោមឱវាទរបស់ **អ.ស.ហ.**<br>– របាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការស្តីពី Bancassurance<br>– របាយការណ៍វឌ្ឍនភាពពាក់ព័ន្ធនឹង ការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹង ការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយ |

| | | | |
|---|---|---|---|
| | | ហិរញ្ញប្បទានដល់ការរីកសាយភាយអារុំធមហាប្រល័យ | អារុំធមហាប្រល័យ |
| ៣.២. | ***កិច្ចសហប្រតិបត្តិការអន្តរជាតិ*** | – ចូលរួមនិងតាមដាន កិច្ចប្រជុំសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– ចូលរួមនិងតាមដានកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– ចូលរួមនិងតាមដាន កិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក | – របាយការណ៍លទ្ធផលនៃកិច្ចប្រជុំសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervision-IAIS)<br>– របាយការណ៍លទ្ធផលនៃកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM)<br>– របាយការណ៍លទ្ធផលនៃកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ានសម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក |

**និយ័តករធានារ៉ាប់រងកម្ពុជា**

**នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

អគារលេខ ១៦៨F (ជាន់ទី៦) ផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ
រាជធានីភ្នំពេញ

gad@irc.gov.kh

@២០២២ រក្សាសិទ្ធិដោយនិយ័តករធានារ៉ាប់រងកម្ពុជា